រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

# ប្លង់មេរៀន

# សកម្មភាពឃុំ សង្កាត់នៅក្នុងកិច្ចការពារកុមារ

354.968
ACT

ខែកក្កដា ឆ្នាំ២០០៦

# មាតិកាអត្ថបទ


កិច្ចចាប់ផ្ដើមនៃវគ្គបណ្ដុះបណ្ដាល ១

កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល ៤

ប្លង់មេរៀនទី១ : កុមារត្រូវការកិច្ចការពារពិសេស ៥

ប្លង់មេរៀនទី២ : កុមារដែលត្រូវគេបោះបង់ចោល និងកុមារកំព្រា ១២

ប្លង់មេរៀនទី៣ : កុមាររស់នៅក្នុងគ្រួសារដែលមានអំពើហិង្សា ១៨

ប្លង់មេរៀនទី៤ : កុមារដែលត្រូវគេរំលោភផ្លូវភេទ ២៣

ប្លង់មេរៀនទី៥ : កុមារត្រូវគេកេងប្រវ័ញ្ចកម្លាំងពលកម្ម ២៩

ប្លង់មេរៀនទី៦ : កុមារចាកចេញពីសហគមន៍ដោយគ្មានឪពុកម្ដាយទៅជាមួយ ៣២

ប្លង់មេរៀនទី៧ : កុមារពិការ ៣៦

ប្លង់មេរៀនទី៨ : កុមារទំនាស់នឹងច្បាប់ ៣៩

ប្លង់មេរៀនទី៩ : បូកសរុបផែនការសកម្មភាព ៤៣

# កិច្ចចាប់ផ្តើមនៃវគ្គបណ្តុះបណ្តាល

មុននឹងចូលដល់មេរៀនទីមួយ អ្នកសម្របសម្រួលអនុវត្តសកម្មភាពមួយចំនួនខាងក្រោម ÷

- ការណែនាំឱ្យស្គាល់គ្នា
- គោលបំណងនៃវគ្គបណ្តុះបណ្តាល
- វិន័យសម្រាប់វគ្គបណ្តុះបណ្តាល
- សិក្ខាកាមដែលចូលរួមវគ្គបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់
- កម្មវិធីបណ្តុះបណ្តាល
- ការណែនាំអំពីរបៀបបំពេញទម្រង់វាយតម្លៃវគ្គបណ្តុះបណ្តាល

## ១). **ការណែនាំឱ្យស្គាល់គ្នា** (ប្រហែល១០នាទី)

អ្នកសម្របសម្រួលអាចប្រើប្រាស់វិធីសាស្ត្រផ្សេងៗ ក្នុងការណែនាំឱ្យស្គាល់គ្នា ដើម្បីឱ្យស្គាល់ឈ្មោះ តួនាទី ទីកន្លែងធ្វើការងារ ឬកន្លែងរស់នៅ ចំណង់ចំណូលចិត្ត . . .។ល។

## ២). **គោលបំណងនៃវគ្គបណ្តុះបណ្តាល**(ប្រហែល៣នាទី)

អ្នកសម្របសម្រួលជម្រាបគោលបំណងនៃវគ្គបណ្តុះបណ្តាលដល់សិក្ខាកាមថា នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមនឹង÷

១. ដឹងអំពីប្រភេទកុមារដែលត្រូវការកិច្ចការពារ និងបញ្ហារបស់ពួកគេ

២. កំណត់បាននូវសេវាសមស្របដើម្បីដោះស្រាយបញ្ហាដែលកើតឡើងចំពោះកុមារនៅក្នុងសហគមន៍

៣. រៀបចំបាននូវផែនការសកម្មភាពដែលក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវអនុវត្តដើម្បីដោះស្រាយបញ្ហាពាក់ព័ន្ធនឹងកិច្ចការពារកុមារ

## ៣). **វិន័យសម្រាប់វគ្គបណ្តុះបណ្តាល** (ប្រហែល៥នាទី)

អ្នកសម្របសម្រួលរួមជាមួយសិក្ខាកាម កំណត់វិន័យសម្រាប់វគ្គបណ្តុះបណ្តាល។

## ៤). **សិក្ខាកាមនៅថ្នាក់ឃុំ សង្កាត់** (ប្រហែល៣នាទី)

ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ ក្នុងមួយវគ្គៗ មានសិក្ខាកាមចូលរួមពី២៥ ទៅ៣០នាក់។ ឃុំ សង្កាត់នីមួយៗ មានចំនួនសិក្ខាកាម៨នាក់ ក្នុងនោះរួមមាន÷

- មេឃុំ ចៅសង្កាត់
- ជំទប់ទី២ ចៅរងទី២
- ស្មៀន
- អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារ
- មេភូមិ ១នាក់
- នគរបាលប៉ុស្តិ៍រដ្ឋបាលឃុំ សង្កាត់
- ព្រះសង្ឃ ឬអាចារ្យវត្ត ឬភ្នាក់ងារស្ម័គ្រចិត្តភូមិ ឬតំណាងអ្នកពាក់ព័ន្ធដទៃទៀត (បើមាន)

## ៥). កម្មវិធីបណ្តុះបណ្តាល (ប្រហែល៥នាទី)

អ្នកសម្របសម្រួលជម្រាបដល់សិក្ខាកាមអំពីកម្មវិធីបណ្តុះបណ្តាល ដូចខាងក្រោម :

| ពេលវេលា | ប្រធានបទ | អ្នកសម្របសម្រួល |
|---|---|---|
| | ថ្ងៃទី១ | |
| 07:30-08:00 | ការមកដល់របស់សិក្ខាកាម និងភ្ញៀវ | |
| 08:00-08:30 | កិច្ចចាប់ផ្តើមនៃវគ្គបណ្តុះបណ្តាល | |
| 08:30-10:00 | មេរៀនទី១ : កុមារត្រូវការកិច្ចការពារពិសេស | |
| 10:00-10:15 | សម្រាកអាហារសម្រន់ | |
| 10:15-11:30 | មេរៀនទី២ : កុមារដែលត្រូវគេបោះបង់ចោល និងកុមារកំព្រា | |
| 11:30-14:00 | សម្រាកអាហារថ្ងៃត្រង់ | |
| 14:00-15:30 | មេរៀនទី៣ : កុមាររស់នៅក្នុងគ្រួសារដែលមានអំពើហិង្សា | |
| 15:30-15:45 | សម្រាកអាហារសម្រន់ | |
| 15.45-17.30 | មេរៀនទី៤ : កុមារដែលត្រូវគេរំលោភផ្លូវភេទ | |
| | ថ្ងៃទី២ | |
| 07:30-08:40 | បន្តមេរៀនទី៥ : កុមារត្រូវគេកេងប្រវ័ញ្ចកម្លាំងពលកម្ម | |
| 08:40-10:10 | មេរៀនទី៦ : កុមារចាកចេញពីសហគមន៍ដោយគ្មានឪពុកម្តាយទៅជាមួយ | |
| 10:10-10:25 | សម្រាកអាហារសម្រន់ | |
| 10:25-11:30 | មេរៀនទី៧ : កុមារពិការ | |
| 11.30-14.00 | សម្រាកអាហារថ្ងៃត្រង់ | |
| 14.00-15:00 | មេរៀនទី៨ : កុមារទំនាស់នឹងច្បាប់ | |
| 15:00-15:15 | សម្រាកអាហារសម្រន់ | |
| 15:15-17.30 | មេរៀនទី៩ : ការបូកសរុបផែនការសកម្មភាព | |

## ៦). ការណែនាំអំពីរបៀបបំពេញទម្រង់វាយតម្លៃវគ្គបណ្តុះបណ្តាល (ប្រហែល៥នាទី)

អ្នកសម្របសម្រួលត្រូវពន្យល់អំពីរបៀបបំពេញទម្រង់វាយតម្លៃ និងរំលឹកដល់សិក្ខាកាមឱ្យបំពេញទម្រង់វាយតម្លៃបន្ទាប់ពីបញ្ចប់មេរៀននីមួយៗ។

# ការវាយតម្លៃវគ្គបណ្តុះបណ្តាលស្តីពីសកម្មភាពឃុំ សង្កាត់នៅក្នុងកិច្ចការពារកុមារ

## (Training Evaluation on Commune/Sangkat Actions on Child Protection)

| មេរៀន Lesson | ខ្លឹមសារមេរៀន Content | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| | អន់ (Bad) | | | | | | | | | ល្អ (Good) |
| 1 | | | | | | | | | | |
| 2 | | | | | | | | | | |
| 3 | | | | | | | | | | |
| 4 | | | | | | | | | | |
| 5 | | | | | | | | | | |
| 6 | | | | | | | | | | |
| 7 | | | | | | | | | | |
| 8 | | | | | | | | | | |
| 9 | | | | | | | | | | |

| មេរៀន Lesson | ការសម្របសម្រួល Facilitation | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| | អន់ (Bad) | | | | | | | | | ល្អ (Good) |
| 1 | | | | | | | | | | |
| 2 | | | | | | | | | | |
| 3 | | | | | | | | | | |
| 4 | | | | | | | | | | |
| 5 | | | | | | | | | | |
| 6 | | | | | | | | | | |
| 7 | | | | | | | | | | |
| 8 | | | | | | | | | | |
| 9 | | | | | | | | | | |

| មេរៀន Lesson | លំហាត់ និងការអនុវត្តជាក់ស្តែង Exercise | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| | អន់ (Bad) | | | | | | | | | ល្អ (Good) |
| 1 | | | | | | | | | | |
| 2 | | | | | | | | | | |
| 3 | | | | | | | | | | |
| 4 | | | | | | | | | | |
| 5 | | | | | | | | | | |
| 6 | | | | | | | | | | |
| 7 | | | | | | | | | | |
| 8 | | | | | | | | | | |
| 9 | | | | | | | | | | |

| មេរៀន Lesson | ពេលវេលា Time | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| | អន់ (Bad) | | | | | | | | | ល្អ (Good) |
| 1 | | | | | | | | | | |
| 2 | | | | | | | | | | |
| 3 | | | | | | | | | | |
| 4 | | | | | | | | | | |
| 5 | | | | | | | | | | |
| 6 | | | | | | | | | | |
| 7 | | | | | | | | | | |
| 8 | | | | | | | | | | |
| 9 | | | | | | | | | | |

| មេរៀន Lesson | កម្រិតយល់ដឹងរបស់សិក្ខាកាម Level of Understanding | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| | អន់ (Bad) | | | | | | | | | ល្អ (Good) |
| 1 | | | | | | | | | | |
| 2 | | | | | | | | | | |
| 3 | | | | | | | | | | |
| 4 | | | | | | | | | | |
| 5 | | | | | | | | | | |
| 6 | | | | | | | | | | |
| 7 | | | | | | | | | | |
| 8 | | | | | | | | | | |
| 9 | | | | | | | | | | |

មតិយោបល់ផ្សេងៗ (Other Comments)

# កំណត់សម្គាល់សម្រាប់អ្នកសម្របសម្រួល

## ១). អ្នកសម្របសម្រួល និងអ្នកគាំទ្រផ្នែកបច្ចេកទេស

ឯកសារបណ្តុះបណ្តាលនេះ ត្រូវបានរៀបចំឡើងសម្រាប់អ្នកដែលមានជំនាញសម្របសម្រួល និងធ្លាប់ពាក់ព័ន្ធនឹងបញ្ហាស្ត្រីនិងកុមារ និងវិមជ្ឈការនៅក្នុងប្រទេសកម្ពុជា ដើម្បីបណ្តុះបណ្តាលបន្តដល់ថ្នាក់ឃុំ សង្កាត់។

អ្នកគាំទ្រផ្នែកបច្ចេកទេស គឺតំណាងមកពីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារខេត្ត ក្រុង ស្រុក ខណ្ឌ។

## ២). តួនាទីរបស់អ្នកសម្របសម្រួល និងអ្នកគាំទ្រផ្នែកបច្ចេកទេស

អ្នកសម្របសម្រួល និងអ្នកគាំទ្រផ្នែកបច្ចេកទេសនឹងបំពេញតួនាទីខុសៗគ្នា ប៉ុន្តែបំពេញឱ្យគ្នាទៅវិញទៅមក ដើម្បីធ្វើឱ្យសិក្ខាកាមរៀនសូត្រប្រកបដោយប្រសិទ្ធភាព។ ជាប្រការមួយសំខាន់គឺ អ្នកសម្របសម្រួលធ្វើការពិភាក្សាជាមួយអ្នកគាំទ្រផ្នែកបច្ចេកទេស មុននឹងដំណើរការវគ្គបណ្តុះបណ្តាលដើម្បីបែងចែកការងារ និងមេរៀនដែលត្រូវសម្របសម្រួល។

ប្លង់មេរៀននេះត្រូវបានធ្វើការបណ្តុះបណ្តាលសាកល្បង និងកែសម្រួលជាច្រើនសារ ហេតុដូចនេះ អ្នកសម្របសម្រួលត្រូវអនុវត្តតាមការណែនាំនៅក្នុងប្លង់មេរៀននេះជាចាំបាច់។ ប្រសិនបើអ្នកសម្របសម្រួលគ្រប់គ្រងពេលវេលាបានល្អ នោះការបណ្តុះបណ្តាលនឹងដំណើរការបានយ៉ាងរលូន ហើយបញ្ចប់តាមការគ្រោងទុក។

### ក). អ្នកសម្របសម្រួល

អ្នកសម្របសម្រួល មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- ត្រៀមរៀបចំឯកសារ និងសម្ភារសម្រាប់ការបណ្តុះបណ្តាល
- គោរព និងអនុវត្តតាមសកម្មភាពដែលបានពិពណ៌នា នៅក្នុងប្លង់មេរៀន
- សម្របសម្រួលការពិភាក្សាជាក្រុម

### ខ). អ្នកគាំទ្រផ្នែកបច្ចេកទេស

អ្នកគាំទ្រផ្នែកបច្ចេកទេស មានតួនាទី និងភារកិច្ច ដូចខាងក្រោម ÷

- សហការជាមួយអ្នកសម្របសម្រួល ក្នុងការបញ្ជាក់បន្ថែមលើខ្លឹមសារបច្ចេកទេស បើចាំបាច់
- សហការជាមួយអ្នកសម្របសម្រួល ក្នុងការសម្របសម្រួលដំណើរការវគ្គបណ្តុះបណ្តាល
- សម្របសម្រួលមេរៀនមួយចំនួន ឬផ្នែកមួយចំនួននៃមេរៀន ទៅតាមការពិភាក្សា និងឯកភាពជាមួយអ្នកសម្របសម្រួល
- សហការជាមួយអ្នកសម្របសម្រួល ក្នុងការសម្របសម្រួលក្រុមពិភាក្សា
- សង្កេតសកម្មភាពបណ្តុះបណ្តាល និងផ្តល់យោបល់ដល់អ្នកសម្របសម្រួល នៅពេលបញ្ចប់មេរៀននីមួយៗ

# ប្លង់មេរៀនទី១
## កុមារត្រូវការកិច្ចការពារពិសេស

| | |
|---|---|
| គោលបំណង | ក្រោយពីបញ្ចប់មេរៀននេះ សិក្ខាកាមនឹង ÷<br>• ដឹងពីប្រភេទកុមារដែលត្រូវការកិច្ចការពារពិសេសនៅក្នុងសហគមន៍<br>• ដឹងពីអត្ថប្រយោជន៍នៃការចុះសំបុត្រកំណើតកុមារ |
| រយៈពេលសរុប | ប្រហែល ៩០នាទី |
| សម្ភារៈ | រូបភាពកុមារស្ថិតក្នុងស្ថានភាពលំបាក សំបុត្រកំណើត១ច្បាប់ ឯកសារ១.១.លំហាត់ ឯកសារ ១.២.ផែនការសកម្មភាពសម្រាប់អាជ្ញាធរមូលដ្ឋាន ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត។ |
| វិធីសាស្ត្រ | បំផុសគំនិត ពិភាក្សាក្រុមតូច មើលរូបភាព ពិភាក្សាក្រុមធំ និងការឡើងបង្ហាញ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ២៥នាទី | **១. ការសួរសំណួរបំផុស**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយសួរសំណួរបំផុសម្តងមួយសំណួរៗ ជាបន្តបន្ទាប់ដូចខាងក្រោម :<br>• តើអ្នកសម្គាល់កុមារបានយ៉ាងដូចម្តេច?<br>• តើកុមារដែលងាយរងគ្រោះមានន័យយ៉ាងដូចម្តេច?<br>• តើកុមារដែលត្រូវការកិច្ចការពារពិសេសមានន័យយ៉ាងដូចម្តេច?<br>• តើការអភិវឌ្ឍរបស់កុមារមានអ្វីខ្លះ?<br>• តើការអភិវឌ្ឍរបស់កុមារមានប៉ុន្មានដំណាក់កាល? មានអ្វីខ្លះ?<br><br>អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់សិក្ខាកាមម្តងមួយសំណួរៗ រួចស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ទំព័រទី៣ (ទាំងអស់) ហើយធ្វើការពន្យល់ម្តងមួយចំណុចៗ។ | ខ្លឹមសារមេរៀន ទំព័រទី៣ |
| ១០នាទី | **២. ពិភាក្សាក្រុមតូច**<br>ដំបូងអ្នកសម្របសម្រួលចែករូបភាពកុមារស្ថិតក្នុងស្ថានភាពលំបាកទី១ ដល់រូបភាពទី៦ (៦រូបភាព) ឱ្យសិក្ខាកាមមើលជាបន្តបន្ទាប់យ៉ាងឆាប់រហ័ស។<br><br>នៅពេលដែលរូបភាពទាំងនោះត្រឡប់មកដល់អ្នកសម្របសម្រួលវិញ អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមដែលអង្គុយក្បែរៗគ្នាចំនួន៣នាក់ ធ្វើការពិភាក្សាដោយសួរសំណួរថា **តើអ្នកបានឃើញអ្វីខ្លះនៅក្នុងរូបភាព?** អ្នកសម្របសម្រួលកត់ត្រា | រូបភាពកុមារស្ថិតក្នុងស្ថានភាពលំបាក (ទី១ ដល់ទី៦) |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ចម្លើយលើក្ដារខៀន ឬលើក្រដាសផ្ទាំងធំ ។<br>**ចម្លើយអាចមាន :**<br>• រូបទី១ : កុមាររស់នៅក្នុងគ្រួសារមានអំពើហិង្សា<br>• រូបទី២ : កុមារដែលត្រូវឪពុកម្ដាយចាកចេញចោល ឬបោះបង់ចោល<br>• រូបទី៣ : កុមារកំព្រា<br>• រូបទី៤ : កុមារញៀនថ្នាំ<br>• រូបទី៥ : កុមារត្រូវគេជួញដូរ<br>• រូបទី៦ : កុមារពិការ | |
| ១០នាទី | **៣. ការសួរសំណួរបំផុស**<br>អ្នកសម្របសម្រួលបន្តដោយបំផុសសំណួរថា **តើអ្នកមានអារម្មណ៍បែបណាចំពោះស្ថានភាពកុមារទាំងនេះ?** អ្នកសម្របសម្រួលកត់ចម្លើយលើក្ដារខៀន ឬលើក្រដាសផ្ទាំងធំ ។<br>**ចម្លើយអាចមានដូចជា :**<br>• កុមារបាត់បង់វ័យកុមារភាព<br>• មិនសប្បាយចិត្ត<br>• អាណិតអាសូរពួកគេ<br>• ចង់ឱ្យសហគមន៍ជួយពួកគេ<br>• ចង់ស្វែងរកនរណាម្នាក់ឬអង្គការណាមួយឱ្យជួយដល់កុមារទាំងនោះ<br>• ចង់ជួយពួកគេ | |
| ២០នាទី | **៤. លំហាត់ និងបង្ហាញ**<br>អ្នកសម្របសម្រួលបញ្ជាក់បន្ថែមទៅសិក្ខាកាមថា ជាធម្មតាកុមារត្រូវបានគេចាត់ទុកថា ជាជនងាយរងគ្រោះពីព្រោះ :<br>• កុមារពឹងផ្អែកយ៉ាងច្រើនលើមនុស្សចាស់ ទាំងខាងផ្លូវចិត្ត ផ្លូវកាយ និងប្រាជ្ញាស្មារតី<br>• កុមារដែលមានវ័យកាន់តែក្មេងកាន់តែងាយរងគ្រោះ<br>• កុមារជឿជាក់យ៉ាងខ្លាំងទៅលើមនុស្សចាស់ ដែលជាហេតុធ្វើឱ្យពួកគេងាយនឹងត្រូវគេបោកបញ្ឆោត រំលោភបំពាន ឬកេងប្រវ័ញ្ចបានយ៉ាងងាយជាងមនុស្សពេញវ័យ ។ | ឯកសារ១.១ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | អ្នកសម្របសម្រួលបន្ថែមទៀតថា ដូចអ្នកបានដឹងហើយថា មានកុមារជាច្រើននៅក្នុងសហគមន៍ គឺជាកុមារដែលងាយរងគ្រោះ ប៉ុន្តែកុមារដែលត្រូវការការអន្តរាគមន៍ជាបន្ទាន់នោះគឺកុមារដែលត្រូវការកិច្ចការពារពិសេស ។<br><br>បន្ទាប់មកអ្នកសម្របសម្រួលចែកឯកសារ១.១ ទៅឱ្យសិក្ខាកាមទាំងអស់ ម្នាក់១សន្លឹក ហើយស្នើឱ្យសិក្ខាកាមរកប្រភេទកុមារត្រូវការកិច្ចការពារពិសេស ដែលមាននៅក្នុងសហគមន៍ឱ្យបានយ៉ាងតិច៥ប្រភេទ ។<br><br>បន្ទាប់ពីសិក្ខាកាមបំពេញរួចហើយ អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាម ២ ឬ ៣នាក់ បង្ហាញលទ្ធផលរបស់ខ្លួន ហើយស្នើឱ្យសិក្ខាកាមដទៃទៀតបន្ថែម បើពួកគេរកឃើញប្រភេទកុមារដែលត្រូវការកិច្ចការពារពិសេសផ្សេងទៀត ។<br><br>បន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅមេរៀនត្រង់ចំណុច **១.១.កុមារដែលត្រូវការកិច្ចការពារពិសេស** ហើយធ្វើការពន្យល់ម្តងមួយចំណុចៗ ។ | ខ្លឹមសារ មេរៀន១.១ |
| ១៥នាទី | **៥. ការសួរសំណួរបំផុសអំពីសារៈប្រយោជន៍នៃសំបុត្រកំណើត**<br>អ្នកសម្របសម្រួលបង្ហាញសំបុត្រកំណើតដល់សិក្ខាមកាម ហើយសួរថា **តើអ្នកដឹងទេ នេះគឺជាអ្វី?** សិក្ខាកាមនឹងឆ្លើយថា នេះជាសំបុត្រកំណើត បន្ទាប់មកសួរបន្តទៀតថា **តើសំបុត្រកំណើតផ្តល់សារៈប្រយោជន៍អ្វីខ្លះដល់កុមារ? ដល់អាជ្ញាធរមូលដ្ឋាន?** អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់សិក្ខាកាមលើក្តារខៀន ឬលើក្រដាសផ្ទាំងធំ ។<br><br>បន្ទាប់មកអ្នកសម្របសម្រួល ស្នើឱ្យសិក្ខាកាមបើកសៀវភៅមេរៀនត្រង់ចំណុច **១.២.សារៈប្រយោជន៍នៃការចុះសំបុត្រកំណើត** ហើយឱ្យសិក្ខាកាមម្នាក់អានឱ្យបានខ្លាំងៗ និងធ្វើការពន្យល់ខ្លឹមសារម្តងមួយចំណុចៗ ។<br><br>អ្នកសម្របសម្រួលបញ្ជាក់ថា នៅជំហានដំបូង ដើម្បីការពារកុមារ គឺត្រូវធានាថា កុមារគ្រប់រូបនៅក្នុងភូមិ ឃុំ សង្កាត់ បានចុះសំបុត្រកំណើត និងទទួលបានសំបុត្រកំណើត ។ បើកុមារកើតមកមិនបានចុះបញ្ជីកំណើត ពួកគេងាយនឹងក្លាយខ្លួនជាកុមារដែលងាយរងគ្រោះ ហើយត្រូវការកិច្ចការពារពិសេស ។ | គំរូសំបុត្រកំណើត<br><br>ខ្លឹមសារ មេរៀន១.២ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១០នាទី | **៦. ការបង្ហាញ និងធ្វើសុពលភាព**<br>អ្នកសម្របសម្រួលចែកឯកសារ ១.២.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមនៅក្នុងឯកសារ ១.២ នូវសកម្មភាពដែលពួកគេចង់បន្ថែមនោះ។ | ឯកសារ១.២. ផែនការ សកម្មភាព |

# រូបភាពកុមារស្ថិតក្នុងស្ថានភាពលំបាក



រូបទី១



រូបទី២



រូបទី៣



រូបទី៤



រូបទី៥



រូបទី៦

## គំរូសំបុត្រកំណើត

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត ក្រុង ....*កណ្ដាល*......
ស្រុក ខណ្ឌ ....*កណ្ដាលស្ទឹង*...
ឃុំ សង្កាត់ ....*គោកត្រប់*.....

លេខ..........*២៥*................
សៀវភៅកំណើតលេខ...*០១/២០០៤*...
ឆ្នាំ............*២០០៤*................

## សំបុត្រកំណើត

| | | | |
|---|---|---|---|
| នាមត្រកូល | | *សម* | ភេទ |
| នាមខ្លួនទារក | | *សិទ្ធី* | *ប្រុស* |
| ជាអក្សរឡាតាំង | នាមត្រកូល | SAM | |
| | នាមខ្លួនទារក | SITHY | |
| សញ្ជាតិ | | *ខ្មែរ* | |
| ថ្ងៃ ខែ ឆ្នាំកំណើត | | *ថ្ងៃ ច័ន្ទ ទី ០៥ ខែ មករា ឆ្នាំ ២០០៤* | |
| ទីកន្លែងកំណើត<br>ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | | ..........*ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុក កណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា*............ | |

| **ឪពុក ម្ដាយទារក** | **ឪពុក** | **ម្ដាយ** |
|---|---|---|
| នាមត្រកូល និងនាមខ្លួន | *សម សោភ័ណ* | *គុណ រតនា* |
| ជាអក្សរឡាតាំង | SAM SORPHORN | KUN RATANA |
| សញ្ជាតិ | *ខ្មែរ* | *ខ្មែរ* |
| ថ្ងៃ ខែ ឆ្នាំកំណើត | *ថ្ងៃទី០១ ខែមេសា ឆ្នាំ១៩៧៥* | *ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ១៩៨០* |
| ទីកន្លែងកំណើត<br>ភូមិ ឃុំសង្កាត់ ស្រុកខណ្ឌ ខេត្តក្រុង ប្រទេស | ...*ភូមិព្រែកកែវ ឃុំកោះខែល ស្រុកស្អាង ខេត្តកណ្ដាល ប្រទេសកម្ពុជា*... | ...*ភូមិពោធិ ឃុំស្លា ស្រុកសំរោង ខេត្តតាកែវ ប្រទេសកម្ពុជា*... |
| ទីលំនៅពេលទារកកើត | .......*ភូមិគោកព្រីង ឃុំគោកត្រប់ ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល ប្រទេសកម្ពុជា*...... | |

ធ្វើនៅ....*គោកត្រប់*..... ថ្ងៃទី *១២* ខែ *មករា* ឆ្នាំ *២០០៤*

**មន្ត្រីអត្រានុកូលដ្ឋាន**
**មេឃុំ**
*ហត្ថលេខា និងត្រា*
*ទ្រី ហៀង*

## ឯកសារ ១.១ : លំហាត់អំពីការកំណត់ប្រភេទកុមារ ដែលត្រូវការកិច្ចការពារពិសេស

ចូរកំណត់ប្រភេទកុមារដែលត្រូវការកិច្ចការពារពិសេសនៅក្នុងសហគមន៍ ឬឃុំ សង្កាត់របស់អ្នកឱ្យបានចំនួន៥ យ៉ាងតិច :

១). ------------------------------------------------------------

២). ------------------------------------------------------------

៣). ------------------------------------------------------------

៤). ------------------------------------------------------------

៥). ------------------------------------------------------------

## ឯកសារ ១.២ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

សកម្មភាពដែលឃុំ សង្កាត់អាចធ្វើបាន :

- ធានាដល់ការផ្តល់នូវការចុះសំបុត្រកំណើតដល់កុមារ តាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ
- ផ្សព្វផ្សាយពីសារៈសំខាន់នៃការចុះសំបុត្រកំណើតដល់ប្រជាពលរដ្ឋនៅក្នុងឃុំ សង្កាត់ ពិសេសគ្រួសារដែលមានកូនតូច ។
- ------------------------------------------------------------
- ------------------------------------------------------------
- ------------------------------------------------------------
- ------------------------------------------------------------
- ------------------------------------------------------------

# ប្លង់មេរៀនទី២
# កុមារដែលត្រូវគេបោះបង់ចោល និងកុមារកំព្រា

| | |
|---|---|
| គោលបំណង | ក្រោយពីបញ្ចប់មេរៀននេះ សិក្ខាកាមនឹង ៖<br>• ដឹងអំពីកុមារកំព្រា និងកុមារដែលត្រូវគេបោះបង់ចោល<br>• ចាត់វិធានការសមស្រប នៅពេលដែលមានកុមារកំព្រា និងកុមារដែលត្រូវគេបោះបង់ចោល នៅក្នុងឃុំ សង្កាត់។ |
| រយៈពេលសរុប | ប្រហែល ៨០នាទី |
| សម្ភារ | ឯកសារ២.១.ករណីសិក្សារឿងរបស់សារឿន ឯកសារ២.២.ករណីសិក្សារឿងរបស់មុំ ឯកសារ២.៣. ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហ្វឺត សុត ក្រដាសផ្ទាំងធំ។ |
| វិធីសាស្ត្រ | បំផុសគំនិត ពិភាក្សាក្រុមតូច ពិភាក្សាក្រុមធំ ការបង្ហាញ និងពន្យល់ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | **១. ការផ្តើមសេចក្តី**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា យើងបានពិភាក្សាជាមួយគ្នាហើយ អំពីកុមារដែលត្រូវការកិច្ចការពារពិសេសដូចជា និយមន័យ ប្រភេទកុមារដែលត្រូវការកិច្ចការពារពិសេស សារៈប្រយោជន៍នៃសំបុត្រកំណើត និងផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន។ ជាបន្តអ្នកសម្របសម្រួលបន្ថែមថា ពេលនេះយើងនឹងពិភាក្សាអំពី **កុមារដែលត្រូវគេបោះបង់ចោល និងកុមារកំព្រា**។ | |
| ៤០នាទី | **២. ការពិភាក្សាក្រុមតូច**<br>អ្នកសម្របសម្រួលចែកសិក្ខាកាមជា៤ក្រុម តាមវិធីសាស្ត្រផ្សេងៗ ហើយចែក :<br>• ឯកសារ២.១. រឿងរបស់សារឿន ទៅក្រុមទី១ និងទីក្រុម២<br>• ឯកសារ២.២. រឿងរបស់មុំ ទៅក្រុមទី៣ និងក្រុមទី៤<br>អ្នកសម្របសម្រួលស្នើឱ្យក្រុមទាំង៤ ធ្វើការពិភាក្សាលើសំណួរដូចខាងក្រោមដែលមានរយៈពេល៣០នាទី :<br>• តើមានបញ្ហាអ្វីកើតឡើងក្នុងករណីសិក្សានេះ?<br>• ហេតុអ្វីបានជាមានបញ្ហានេះកើតឡើង?<br>• នៅពេលបញ្ហានេះកើតឡើង តើវាបានផ្តល់ផលប៉ះពាល់អ្វីខ្លះ?<br>• តើអ្នកអាចធ្វើអ្វីខ្លះបាន ដើម្បីដោះស្រាយបញ្ហានេះបាន? | ឯកសារ២.១. ករណីសិក្សារឿងរបស់សារឿន<br><br>ឯកសារ២.២. ករណីសិក្សារឿងរបស់មុំ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|

ក្រុមនីមួយៗត្រូវជ្រើសរើសអ្នកសម្របសម្រួលការពិភាក្សា អ្នកកត់ត្រាលើក្រដាសផ្ទាំងធំតាមតារាងដូចខាងក្រោម និងអ្នកឡើងបង្ហាញ ។

| បញ្ហា | មូលហេតុ | ផលប៉ះពាល់ | ដំណោះស្រាយ |
|---|---|---|---|
| | | | |

ជាបន្តអ្នកសម្របសម្រួលជ្រើសរើសមួយក្រុម ឡើងបង្ហាញលទ្ធផលនៃការពិភាក្សាករណីសិក្សារឿងរបស់សារឿន និងមួយក្រុមទៀតឡើងបង្ហាញលទ្ធផលក្រុមពិភាក្សាករណីសិក្សារឿងរបស់មុំ ។ ដោយឡែកពីរក្រុមផ្សេងទៀតត្រូវជួយបន្ថែមចម្លើយនៅតាមក្រុមនីមួយៗ (បើមានអ្វីបន្ថែម) ។

**ចម្លើយអាចមានសម្រាប់រឿងរបស់សារឿន**

| បញ្ហា | មូលហេតុ | ផលប៉ះពាល់ | ដំណោះស្រាយ |
|---|---|---|---|
| • កុមារកំព្រា | • ឪពុកម្ដាយស្លាប់ | • ឈប់ទៅរៀន<br>• គ្មានអ្នកថែទាំ | • ស្វែងរកសាច់ញាតិរបស់សារឿនដើម្បីឱ្យថែទាំគេ<br>• ស្វែងរកឪពុកម្ដាយចិញ្ចឹម<br>• ទំនាក់ទំនងមន្ត្រីសង្គមកិច្ច ឱ្យជួយបញ្ជូនសារឿនទៅរកសេវាសមស្របបើចាំបាច់ |

**ចម្លើយអាចមានសម្រាប់រឿងរបស់មុំ**

| បញ្ហា | មូលហេតុ | ផលប៉ះពាល់ | ដំណោះស្រាយ |
|---|---|---|---|
| • ក្រីក្រខ្លាំង<br>• ឪពុកចាកចេញពីផ្ទះ | • គ្មានដីស្រែ<br>• ទៅរកការងារ<br>• បាត់ដំណឹងឪពុកម្ដាយ | • មិនបានទៅសាលារៀន<br>• គ្មានសម្ភារសិក្សា និងសម្លៀកបំពាក់គ្រប់គ្រាន់<br>• គ្មានអាហារបរិភោគគ្រប់គ្រាន់<br>• កូនទាំងបីត្រូវម្ដាយបោះបង់ចោល | • ស្វែងរកឪពុកម្ដាយ<br>• ស្វែងរកសាច់ញាតិរបស់មុំដើម្បីឱ្យថែទាំពួកគេ<br>• ទំនាក់ទំនងជាមួយអាចារ្យវត្ត ឬព្រះសង្ឃដើម្បីផ្ដល់អាហារដល់កុមារទាំងនោះ<br>• ទំនាក់ទំនងនាយកសាលាដើម្បីឱ្យទទួលពួកគេចូលរៀនវិញ<br>• ផ្ដល់ព័ត៌មានទៅអាជ្ញាធរ ឬមន្ត្រីសង្គមកិច្ចស្រុកដើម្បីស្វែងរកឪពុកម្ដាយ និងរកសេវាសមស្របក្នុងករណីចាំបាច់ ។ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ២៥នាទី | **៣. ការបំផុសសំណួរ និងការបង្ហាញ-ពន្យល់ខ្លឹមសារមេរៀនទី២**<br>អ្នកសម្របសម្រួលបំផុសសំណួរ :<br>• តើកុមារកំព្រារមានន័យដូចម្តេច?<br>• តើកុមារដែលគេបោះបង់ចោលមានន័យដូចម្តេច?<br>• តើមានដំណោះស្រាយអ្វីខ្លះដើម្បីជួយដល់កុមារដែលត្រូវគេបោះបង់ចោល និងកុមារកំព្រា?<br>អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់សិក្ខាកាមនៅលើក្រដាសផ្ទាំងធំ។<br><br>បន្ទាប់មកអ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់មេរៀនទី២ "កុមារដែលត្រូវគេបោះបង់ចោល និងកុមារកំព្រារ" (ទំព័រទី៧-៩) ហើយធ្វើការបង្ហាញ (អ្នកសម្របសម្រួលអានខ្លួនឯង ឬឱ្យសិក្ខាកាមអាន) និងពន្យល់ម្តងមួយចំណុចៗ។ | ខ្លឹមសារមេរៀនទី២ (ទំព័រ៧-៩) |
| ១០នាទី | **៤. ការបង្ហាញ និងធ្វើសុពលភាព**<br>អ្នកសម្របសម្រួលចែកឯកសារ **២.៣.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន** ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។<br>អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមនៅក្នុងឯកសារ ២.៣ នូវសកម្មភាពដែលគេចង់បន្ថែមនោះ។ | ឯកសារ ២.៣. ផែនការសកម្មភាព |

# ឯកសារ ២.១ : ករណីសិក្សារឿងរបស់សារឿន

សារឿនមានអាយុ១០ឆ្នាំ រស់នៅក្នុងគ្រួសារក្រីក្រមួយដែលមានម្ដាយជាស្ត្រីមេម៉ាយ និងប្អូន១ ២នាក់ទៀត។ ចំណែកឯឪពុកសារឿនបានស្លាប់ចោលតាំងពីសារឿនមានអាយុ៦ឆ្នាំម្លេះ។ ទោះបីជាគ្រួសារមានជីវភាពក្រីក្រយ៉ាងខ្លាំងក៏ដោយ ក៏ម្ដាយសារឿននៅតែខំប្រឹងប្រែងចិញ្ចឹម និងថែទាំពួកគេ ហើយបានឱ្យសារឿនចូលរៀននៅពេលគេមានអាយុ៧ឆ្នាំ។ សារឿនបានប្រាប់ម្ដាយថា ខ្លួនចង់ក្លាយជាវេជ្ជបណ្ឌិត។

កាលពី២ខែមុន ម្ដាយរបស់សារឿនធ្លាក់ខ្លួនឈឺជាទម្ងន់។ សារឿន និងអ្នកជិតខាងមួយចំនួនខិតខំព្យាយាមមើលថែគាត់ ប៉ុន្តែគាត់កាន់តែធ្ងន់ធ្ងរទៅៗ ហើយមិនយូរប៉ុន្មានគាត់មិនអាចធ្វើការបានតទៅទៀត។ ទីបំផុតអ្នកជិតខាងបានជួយចេញប្រាក់ដើម្បីនាំគាត់ទៅកាន់មន្ទីរពេទ្យបង្អែកស្រុក។ ប៉ុន្តែយឺតពេលទៅហើយ គាត់មានជំងឺមហារីក ក្នុងស្ថានភាពធ្ងន់ធ្ងរ។

សារឿនឈប់ទៅរៀនដើម្បីទុកពេលវេលាសម្រាប់ថែទាំម្ដាយ។ ជាអកុសលម្ដាយសារឿនក៏លាចាកលោកនេះទៅទុកអោយសារឿន និងប្អូនទាំងពីរនាក់ទៀតកើតទុក្ខក្រៀមក្រំ និងឯកោ។

## សំណួរសម្រាប់ពិភាក្សា :

- តើមានបញ្ហាអ្វីកើតឡើងក្នុងករណីសិក្សានេះ?
- ហេតុអ្វីបានជាមានបញ្ហានេះកើតឡើង?
- នៅពេលបញ្ហានេះកើតឡើង តើវាបានផ្ដល់ផលប៉ះពាល់អ្វីខ្លះ?
- តើអ្នកអាចធ្វើអ្វីខ្លះបាន ដើម្បីដោះស្រាយបញ្ហានេះបាន?

| បញ្ហា | មូលហេតុ | ផលប៉ះពាល់ | ដំណោះស្រាយ |
|---|---|---|---|
| | | | |

## ឯកសារ ២.២ : ករណីសិក្សារឿងរបស់មុំ

មុំមានអាយុ៨ឆ្នាំ រស់នៅជាមួយឪពុកម្តាយ និងបងប្អូនប្រុស២នាក់។ គ្រួសារនាងក្រីក្រខ្លាំងណាស់ ដោយសារគ្មានដីស្រែ។ ឪពុកនាងរកប្រាក់ដោយការស៊ីឈ្នួលធ្វើការឱ្យគេ។ មុំ និងបងប្អូននាងមិនបានទៅរៀន ដោយសារតែឪពុក ម្តាយពុំមានលទ្ធភាពចំណាយលើថ្លៃសម្ភារសិក្សា និងសម្លៀកបំពាក់សិស្សសាលាបាន។ ពេលខ្លះម្តាយមុំខឹងនឹងឪពុកនាងដែលរកប្រាក់មិនបានគ្រប់គ្រាន់។

ថ្ងៃមួយឪពុកមុំបានដឹងថាមានការងារនៅការដ្ឋានសំណង់នៅទីក្រុង។ គាត់ប្រាប់ម្តាយមុំថា ប្រសិនបើគាត់ទៅធ្វើការនៅទីនោះ គាត់នឹងអាចរកប្រាក់បានច្រើនផ្ញើមកផ្ទះជារៀងរាល់សប្តាហ៍។ ទោះបីជាមិនចង់ឃើញប្តីរបស់ខ្លួនចាកចេញទៅក៏ដោយ ក៏ម្តាយមុំគិតថាពួកគាត់គ្មានជម្រើសឡើយ ហើយសប្បាយចិត្ត ដោយសង្ឃឹមថា ប្តីគាត់អាចរកប្រាក់បានច្រើន។ ឪពុកមុំក៏ចាកចេញទៅកាន់ទីក្រុងដើម្បីធ្វើការនៅការដ្ឋានសំណង់នោះកាលពីឆ្នាំកន្លងទៅ។ ដំបូង គាត់បានផ្ញើប្រាក់មកអោយគ្រួសារជារៀងរាល់២-៣សប្តាហ៍ម្តង តែក្រោយមកពួកគេក៏លែងបានទទួលដំណឹងអ្វីពីគាត់ និងមិនឃើញគាត់ត្រឡប់មកផ្ទះវិញឡើយ។ ទីបំផុតម្តាយមុំបានសម្រេចចិត្តទៅតាមរកឪពុកមុំនៅទីក្រុង។ គាត់បានប្រាប់មុំ និងកូនប្រុសទាំងពីរថា គាត់នឹងត្រឡប់មកផ្ទះវិញក្នុងរយៈពេលមួយសប្តាហ៍ ហើយគាត់ទុកអាហារគ្រប់គ្រាន់នៅផ្ទះសម្រាប់ពួកគេទទួលទាន។ ឥឡូវនេះគឺ២ខែបានកន្លងផុតទៅហើយ ឪពុកម្តាយមុំមិនត្រឡប់មកវិញឡើយ។ ពួកគេត្រូវខ្ចីអាហារពីអ្នកជិតខាង និងបន្ទាប់មកពីព្រះសង្ឃដើម្បីបរិភោគ។

### សំណួរសម្រាប់ពិភាក្សា :

- តើមានបញ្ហាអ្វីកើតឡើងក្នុងករណីសិក្សានេះ?
- ហេតុអ្វីបានជាមានបញ្ហានេះកើតឡើង?
- នៅពេលបញ្ហានេះកើតឡើង តើវាបានផ្តល់ផលប៉ះពាល់អ្វីខ្លះ?
- តើអ្នកអាចធ្វើអ្វីខ្លះបាន ដើម្បីដោះស្រាយបញ្ហានេះបាន?

| បញ្ហា | មូលហេតុ | ផលប៉ះពាល់ | ដំណោះស្រាយ |
|---|---|---|---|
| | | | |

## ឯកសារ ២.៣ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- ជួយស្វែងរកឪពុកម្ដាយ ឬសាច់ញាតិ ដើម្បីផ្ដល់ការថែទាំកុមារ
- ទំនាក់ទំនងជាមួយអាចារ្យវត្ត ព្រះសង្ឃ ឬអង្គការ ស្ថាប័ននានា ដើម្បីផ្ដល់អាហារ និងទីជម្រកដល់កុមារ
- ទំនាក់ទំនងជាមួយនាយកសាលា ដើម្បីឱ្យកុមារអាចចូលរៀនបាន
- ផ្ដល់ព័ត៌មានទៅអាជ្ញាធរ ឬមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌដើម្បីស្វែងរកឪពុកម្ដាយ និងរកសេវាសមស្រប នានាក្នុងករណីចាំបាច់ ។
- ------------------------------------------------------------
- ------------------------------------------------------------
- ------------------------------------------------------------
- ------------------------------------------------------------
- ------------------------------------------------------------

# ប្លង់មេរៀនទី៣
# កុមាររស់នៅក្នុងគ្រួសារដែលមានអំពើហិង្សា

| | |
|---|---|
| គោលបំណង | ក្រោយពីបញ្ចប់មេរៀននេះ សិក្ខាកាមនឹង ÷<br>• ដឹងពីផលប៉ះពាល់ជាអវិជ្ជមាននៃអំពើហិង្សាក្នុងគ្រួសារចំពោះកុមារ<br>• ដឹងពីសេវាសមស្របនានាសម្រាប់ជួយកុមាររស់នៅក្នុងគ្រួសារដែលមានអំពើហិង្សា<br>• បង្កើតផែនការសកម្មភាពដើម្បីជួយដល់កុមាររងគ្រោះ |
| រយៈពេលសរុប | ប្រហែល ៨៥នាទី |
| សម្ភារៈ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ឯកសារ៣.១.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ផ្ទាំងរូបភាពស្ដីពីអំពើហិង្សាក្នុងគ្រួសារចំនួន៩ផ្ទាំងរូបភាព |
| វិធីសាស្ត្រ | បំផុសគំនិត មើលផ្ទាំងរូបភាព ពិភាក្សាក្រុមតូច ពិភាក្សាក្រុមធំ ការបង្ហាញ និងពន្យល់ |

សកម្មភាពសម្របសម្រួលមេរៀន :

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | **១. ការផ្ដើមសេចក្ដី**<br>អ្នកសម្របសម្រួលចាប់ផ្ដើមដោយលើកឡើងថា យើងបានពិភាក្សាជាមួយគ្នាហើយអំពីកុមារដែលត្រូវការកិច្ចការពារពិសេស និងកុមារកំព្រានិងកុមារគេបោះបង់ចោល ។<br>ជាបន្តអ្នកសម្របសម្រួលបន្ថែមថា ពេលនេះយើងនឹងពិភាក្សាអំពីកុមាររស់នៅក្នុងគ្រួសារដែលមានអំពើហិង្សា ។ | |
| ៥នាទី | **២. ការសួរសំណួរបំផុសអំពីអំពើហិង្សាក្នុងគ្រួសារ**<br>អ្នកសម្របសម្រួលចាប់ផ្ដើមដោយសួរសំណួរថា តើអំពើហិង្សាក្នុងគ្រួសារមានន័យយ៉ាងដូចម្ដេច? កត់ត្រាចម្លើយលើក្ដារខៀន ឬក្រដាសផ្ទាំងធំ ។ បន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលបញ្ជាក់ថា "អំពើហិង្សាក្នុងគ្រួសារ សំដៅលើអំពើហិង្សា ឬការរំលោភបំពានផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត និងផ្នែកជីវភាពសេដ្ឋកិច្ចដែលត្រូវបានប្រព្រឹត្តដោយមនុស្សម្នាក់ ឬច្រើននាក់ ដើម្បីត្រួតត្រាលើមនុស្សផ្សេងទៀត ដែលកំពុងរស់នៅក្នុងគ្រួសារនោះ" (ខ្លឹមសារនេះមាននៅសៀវភៅមេរៀនទំព័រទី១០) ។ | |
| ៣៥នាទី | **៣. ការពិភាក្សាលើផ្ទាំងរូបភាព និងការបំផុសសំណួរ**<br>អ្នកសម្របសម្រួលបង្ហាញផ្ទាំងរូបភាពអំពីអំពើហិង្សាក្នុងគ្រួសារទៅក្រុមធំម្ដងមួយផ្ទាំង។ (ចំនួន៩) ដោយមិនចាំបាច់ពន្យល់អ្វីឡើយ នៅពេលបង្ហាញចប់ សួរទៅកាន់សិក្ខាកាមថា : | ផ្ទាំងរូបភាពអំពើហិង្សាក្នុងគ្រួសារ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | • តើអ្នកបានឃើញអ្វីខ្លះនៅក្នុងផ្ទាំងរូបភាពនេះ?<br>• តើរូបភាពនីមួយៗមានន័យយ៉ាងដូចម្ដេច?<br>• តើបញ្ហានេះធ្លាប់កើតមាននៅក្នុងសហគមន៍អ្នកដែរឬទេ? បើមានសូមលើកឧទាហរណ៍<br><br>ជៀសវាងខាតពេលវេលាច្រើនអ្នកសម្របសម្រួល មិនចាំបាច់កត់ត្រាចម្លើយលើក្ដារខៀន ឬក្រដាសផ្ទាំងធំឡើយ។<br>**ចម្លើយអាចមាន :**<br>• រូបទី១ : ការរំលោភបំពានផ្លូវចិត្ត<br>• រូបទី២ : ការរំលោភបំពានលើរាងកាយ<br>• រូបទី៣ : ផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារលើកុមារ<br>• រូបទី៤ : មូលហេតុបណ្ដាលឱ្យមានអំពើហិង្សាក្នុងគ្រួសារ (ឥទ្ធិពលសង្គម ទម្លាប់ និងការញៀន)<br>• រូបទី៥ : មូលហេតុបណ្ដាលឱ្យមានអំពើហិង្សាក្នុងគ្រួសារ (ការរំសាយកំហឹង និងអំណាច ឬការត្រួតត្រា)<br>• រូបទី៦ : វិធានការចំពោះជនមុខសញ្ញាដែលប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ<br>• រូបទី៧ : ផលប៉ះពាល់នៃអំពើហិង្សាលើជនរងគ្រោះ<br>• រូបទី៨ : របៀបបង្ការ និងការពារស្ត្រី និងកុមារពីអំពើហិង្សាក្នុងគ្រួសារ<br>• រូបទី៩ : របៀបបង្ការ និងទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ | ចំនួន៩ |
| | អ្នកសម្របសម្រួលសួរសំណួរបន្តថា តើអំពើហិង្សាក្នុងគ្រួសារផ្ដល់ផលប៉ះពាល់អ្វីខ្លះលើកុមារ? កត់ត្រាចម្លើយលើក្ដារខៀន ឬក្រដាសផ្ទាំងធំ។ បន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៣.១.ផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារលើកុមារ ហើយឱ្យសិក្ខាកាមម្នាក់អានខ្លាំងៗ រួចធ្វើការពន្យល់ម្ដងមួយចំណុចៗ។ | ខ្លឹមសារមេរៀន ៣.១ |
| ៣០នាទី | **៤. ការសួរសំណួរបំផុស និងបង្ហាញ**<br>អ្នកសម្របសម្រួលបន្តដោយសួរសំណួរទៅសិក្ខាកាមថា តើអ្នកគួរធ្វើយ៉ាងណានៅពេលមានអំពើហិង្សាក្នុងគ្រួសារដែលប៉ះពាល់ដល់កុមារកើតឡើងនៅក្នុងឃុំ សង្កាត់របស់អ្នក? កត់ត្រាចម្លើយលើក្ដារខៀន ឬក្រដាសផ្ទាំងធំ។ | ខ្លឹមសារមេរៀន ៣.២ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | បន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៣.២.ដំណោះស្រាយ ហើយឱ្យសិក្ខាកាមម្នាក់អានឱ្យបានខ្លាំងៗ និងធ្វើការពន្យល់ម្តងមួយចំណុចៗ។ | |
| ១០នាទី | **៥. ការបង្ហាញ និងធ្វើសុពលភាព**<br>អ្នកសម្របសម្រួលចែកឯកសារ ៣.១.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមនៅក្នុងឯកសារ ៣.១ នូវសកម្មភាពដែលគេចង់បន្ថែមនោះ។ | ឯកសារ ៣.១. ផែនការសកម្មភាព |

## រូបភាពអំពើហិង្សាក្នុងគ្រួសារ



រូបទី១



រូបទី២



រូបទី៣



រូបទី៤



រូបទី៥



រូបទី៦



រូបទី៧



រូបទី៨



រូបទី៩

## ឯកសារ ៣.១ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- មេភូមិលើកទឹកចិត្តជនរងគ្រោះឱ្យរាយការណ៍មកខ្លួន ឬទៅភ្នាក់ងារស្ម័គ្រចិត្តភូមិ
- មេភូមិពន្យល់ណែនាំដល់អ្នកប្រព្រឹត្តអំពើហិង្សា
- មេភូមិ និងជំទប់ទី២ ឬភ្នាក់ងារស្ម័គ្រចិត្តភូមិត្រូវរាយការណ៍ពីករណីនោះទៅមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ និងទៅនគរបាលប៉ុស្តិ៍រដ្ឋបាល ដើម្បីសុំអន្តរាគមន៍ និងបញ្ជូនជនរងគ្រោះទៅរកសេវាប្រឹក្សាយោបល់
- ផ្តល់ប្រឹក្សា និងពិគ្រោះយោបល់ដល់ជនរងគ្រោះ និងជនមុខសញ្ញា
- ឃ្លាំមើល ឬតាមដានអ្នកដែលប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ
- ជួយ និងផ្តល់ព័ត៌មានជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋានមានសមត្ថកិច្ច
- ------------------------------------------------------------------------
- ------------------------------------------------------------------------
- ------------------------------------------------------------------------
- ------------------------------------------------------------------------
- ------------------------------------------------------------------------

# ប្លង់មេរៀនទី៤
# កុមារដែលត្រូវគេរំលោភផ្លូវភេទ

| | |
|---|---|
| គោលបំណង | ក្រោយពីបញ្ចប់មេរៀននេះ សិក្ខាកាមនឹង ÷<br>• ដឹងពីផលប៉ះពាល់ជាអវិជ្ជមាននៃការរំលោភផ្លូវភេទលើកុមារ<br>• ដឹងពីល្បិចកលរបស់ជនល្មើស<br>• ចាត់វិធានការសមស្របដើម្បីទប់ស្កាត់ការរំលោភផ្លូវភេទលើកុមារនៅក្នុងឃុំ សង្កាត់របស់ខ្លួន |
| រយៈពេលសរុប | ប្រហែល ៩៥នាទី |
| សម្ភារ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ក្រដាសកាត ឯកសារ៤.១.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ផ្ទាំងរូបភាពស្ដីពីការរំលោភផ្លូវភេទលើកុមារចំនួន១១ផ្ទាំងរូបភាព |
| វិធីសាស្ត្រ | បំផុសគំនិត ពិភាក្សាជាគូ ពិភាក្សាក្រុមធំ ការបង្ហាញ និងពន្យល់ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | **១. ការសួរសំណួរបំផុស**<br>អ្នកសម្របសម្រួលចាប់ផ្ដើមដោយសួរសំណួរបំផុសថា **តើការរំលោភផ្លូវភេទលើកុមារមានន័យយ៉ាងដូចម្ដេច?** កត់ត្រាចម្លើយរបស់សិក្ខាកាម។ បន្ទាប់មកអ្នកសម្របសម្រួលបន្ថែមថា "ការរំលោភផ្លូវភេទលើកុមារ គឺជាសកម្មភាពនៃការរំលោភសេពសន្ថវៈ ការបៀតបៀនកេរ្តិ៍ខ្មាស ការប្រព្រឹត្តអំពើអាស្រូវភាស និងសកម្មភាពរំលោភផ្លូវភេទផ្សេងទៀតដើម្បីបន្ទាបបន្ថោកដល់កុមារ ទោះជាកុមារនោះព្រម ឬមិនព្រមក្ដី" (ខ្លឹមសារនេះមាននៅក្នុងសៀវភៅមេរៀនទំព័រទី១៥)។ | |
| ៣៥នាទី | **២. ការពិភាក្សាលើផ្ទាំងរូបភាព និងការបំផុសសំណួរ**<br>អ្នកសម្របសម្រួល បង្ហាញផ្ទាំងរូបភាពអំពីការរំលោភផ្លូវភេទលើកុមារទៅក្រុមធំម្ដងមួយផ្ទាំងៗ (ចំនួន១១) ដោយមិនចាំបាច់ពន្យល់អ្វីឡើយ។ នៅពេលបង្ហាញចប់សួរទៅកាន់សិក្ខាកាមថា :<br>• តើអ្នកបានឃើញអ្វីខ្លះនៅក្នុងផ្ទាំងរូបភាពនេះ?<br>• តើរូបភាពនីមួយៗមានន័យយ៉ាងដូចម្ដេច?<br>• តើបញ្ហានេះធ្លាប់កើតមាននៅក្នុងសហគមន៍អ្នកដែរឬទេ? បើមានសូមលើកឧទាហរណ៍។ | ផ្ទាំងរូបភាពការរំលោភផ្លូវភេទលើកុមារចំនួន១១ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ជៀសវាងខាតពេលវេលាច្រើនអ្នកសម្របសម្រួល មិនចាំបាច់កត់ត្រាចម្លើយលើក្ដារខៀន ឬក្រដាសផ្ទាំងធំឡើយ ។<br><br>**ចម្លើយអាចមាន :**<br>• រូបទី១ : ការរំលោភផ្លូវភេទលើកុមារ<br>• រូបទី២ : ការដោះស្រាយបញ្ហានៃការរំលោភផ្លូវភេទលើកុមារដោយសំណងជាលុយ ឬសម្ភារៈ<br>• រូបទី៣ : ការដោះស្រាយបញ្ហានៃការរំលោភផ្លូវភេទលើកុមារ ដោយរៀបអាពាហ៍ពិពាហ៍<br>• រូបទី៤ : ការរំលោភជាក្រុម<br>• រូបទី៥ : ការប្ដឹងទៅនគរបាល<br>• រូបទី៦ : ការប្រមូលភស្តុតាងនានា<br>• រូបទី៧ : ការពិនិត្យ និងធ្វើកោសល្យវិច័យ<br>• រូបទី៨ : ជំនួយផ្នែកចិត្តសាស្ត្រសង្គម<br>• រូបទី៩ : មេធាវី<br>• រូបទី១០ : ការកាត់ទោស<br>• រូបទី១១ : វិធានការការពារ | |
| ១៥នាទី | **៣. ការសួរសំណួរបំផុស និងបង្ហាញ**<br>អ្នកសម្របសម្រួលបន្តដោយសួរសំណួរថា តើការរំលោភផ្លូវភេទផ្ដល់ផលប៉ះពាល់អ្វីខ្លះដល់កុមារ? ក្នុងការបំផុសសំណួរ អ្នកសម្របសម្រួលត្រូវប្រើក្រដាសកាតមួយគំនិតមួយ ដោយចែកក្រដាសកាតទៅឱ្យសិក្ខាកាមម្នាក់០១សន្លឹក ហើយស្នើឱ្យសិក្ខាកាមសរសេរចម្លើយតែ០១ប៉ុណ្ណោះ។ ពេលសិក្ខាកាមសរសេរចម្លើយ រួចហើយអ្នកសម្របសម្រួលប្រមូល ហើយបិទនៅលើក្ដារខៀន និងធ្វើការសរុបលទ្ធផល។<br><br>ប្រសិនបើចម្លើយរបស់សិក្ខាកាមមិនទាន់គ្រប់គ្រាន់ អ្នកសម្របសម្រួលបន្ថែមដោយស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៤.១.ផលប៉ះពាល់នៃការរំលោភផ្លូវភេទលើកុមារ ហើយធ្វើការពន្យល់ម្ដងមួយចំណុចៗ។ | ក្រដាសកាត<br><br>ខ្ទឹមសារ មេរៀន ៤.១ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១៥នាទី | **៤. ការពិភាក្សាជាដៃគូ**<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមអង្គុយក្បែរៗគ្នា២នាក់ៗ ធ្វើការពិភាក្សាលើសំណួរ តើជនល្មើសប្រើល្បិចកល ឬមធ្យោបាយអ្វីខ្លះដើម្បីទាក់ទាញជនរងគ្រោះ?<br>ក្នុងការពិភាក្សានេះ អ្នកសម្របសម្រួលត្រូវចែកក្រដាសកាតទៅឱ្យគូនីមួយៗ។ បន្ទាប់ពីគូនីមួយៗពិភាក្សាចប់ អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាម៤ ទៅ៥គូអានលទ្ធផលរបស់ខ្លួន ហើយស្នើឱ្យគូផ្សេងទៀតបន្ថែម បើគេមានអ្វីបន្ថែម។<br>ប្រសិនបើចម្លើយរបស់សិក្ខាកាមមិនទាន់គ្រប់គ្រាន់ អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅមេរៀនត្រង់ចំណុច ៤.២.ល្បិចកលជនល្មើស ហើយធ្វើការពន្យល់ម្តងមួយចំណុចៗ។ | ក្រដាសកាត<br><br>ខ្លឹមសារ មេរៀន ៤.២ |
| ១៥នាទី | **៥. ការសួរសំណួរបំផុស**<br>អ្នកសម្របសម្រួលសួរទៅសិក្ខាកាមថា តើអ្នកអាចធ្វើអ្វីបានខ្លះនៅពេលដែលទទួលបានព័ត៌មានអំពីករណីរំលោភផ្លូវភេទលើកុមារភ្លាមៗ? កត់ត្រាចម្លើយរបស់សិក្ខាកាម។ ដើម្បីឱ្យសិក្ខាកាមបានយល់កាន់តែច្បាស់ អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅមេរៀនត្រង់ចំណុច ៤.៣.ការអន្តរាគមន៍ករណីការរំលោភផ្លូវភេទលើកុមារ ហើយធ្វើការពន្យល់ម្តងមួយចំណុចៗ។ | ខ្លឹមសារ មេរៀន ៤.៣ |
| ១០នាទី | **៦. ការបង្ហាញ និងធ្វើសុពលភាព**<br>អ្នកសម្របសម្រួលចែកឯកសារ ៤.១.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមនៅក្នុងឯកសារ ៤.១ នូវសកម្មភាពដែលគេចង់បន្ថែមនោះ។ | ឯកសារ៤.១. ផែនការ សកម្មភាព |

# រូបភាពស្តីពីការរំលោភផ្លូវភេទ



រូបទី១



រូបទី២



រូបទី៣



រូបទី៤



រូបទី៥



រូបទី៦



រូបទី៧



រូបទី៨



រូបទី៩



រូបទី១០



រូបទី១១

## ឯកសារ ៤.១ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- លើកកម្ពស់ការយល់ដឹងជាសាធារណៈអំពីផលវិបាកនៃការរំលោភផ្លូវភេទ និងល្បិចកលជនល្មើស
- លើកកម្ពស់ការយល់ដឹងរបស់គ្រូបង្រៀនអំពីអាការៈរបស់កុមារ ដែលត្រូវគេចាប់រំលោភ
- ផ្សព្វផ្សាយអំពីទីកន្លែងផ្តល់ប្រឹក្សាយោបល់ និងសេវាថែទាំសុខភាព។ បើកន្លែងនោះនៅឆ្ងាយ គួរកៀរគររកធនធានដើម្បីជួយជាមធ្យោបាយធ្វើដំណើរដល់ជនរងគ្រោះឱ្យទទួលសេវានោះបាន
- បញ្ជូនកុមាររងគ្រោះទៅមន្ទីរពេទ្យ និងទៅមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ
- ផ្តល់ការគាំទ្រ និងលើកទឹកចិត្តដល់ជនរងគ្រោះ
- លើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីទំនាក់ទំនងផ្លូវភេទជាមួយកុមារថា ជាអំពើខុសច្បាប់ ទោះបីមានការយល់ព្រមពីកុមារក៏ដោយ
- ផ្តល់ដំណឹងទៅនគរបាល និងអាជ្ញាធរមានសមត្ថកិច្ច
- ឃាត់ខ្លួនជនល្មើសរួចបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច
- ------------------------------------------------------------
- ------------------------------------------------------------
- ------------------------------------------------------------
- ------------------------------------------------------------
- ------------------------------------------------------------
- ------------------------------------------------------------

# ប្លង់មេរៀនទី៥
# កុមារត្រូវគេកេងប្រវ័ញ្ចកម្លាំងពលកម្ម

| | |
|---|---|
| គោលបំណង | ក្រោយពីបញ្ចប់មេរៀននេះ សិក្ខាកាមនឹង÷<br>• ដឹងពីប្រភេទការងារដែលនាំឱ្យមានគ្រោះថ្នាក់ដល់កុមារ<br>• ដឹងពីផលប៉ះពាល់ជាអវិជ្ជមានលើកុមារដែលត្រូវគេកេងប្រវ័ញ្ចកម្លាំងពលកម្ម<br>• ចាត់វិធានការដើម្បីដោះស្រាយបញ្ហាការកេងប្រវ័ញ្ចកម្លាំងពលកម្មនៅក្នុងឃុំ សង្កាត់របស់ខ្លួន |
| រយៈពេលសរុប | ប្រហែល ៦៥នាទី |
| សម្ភារ | ក្រដាសផ្ទាំងធំ ហ្វឹត ស្កុត ក្រដាសកាត ឯកសារ៥.១.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន |
| វិធីសាស្ត្រ | បំផុសគំនិត ការបង្ហាញ និងពន្យល់ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | **១. ផ្ដើមសេចក្ដី**<br>អ្នកសម្របសម្រួលចាប់ផ្ដើមដោយលើកឡើងថា យើងបានពិភាក្សាជាមួយគ្នាហើយអំពីកុមារដែលត្រូវការកិច្ចការពារពិសេស កុមារកំព្រានិងកុមារគេបោះបង់ចោល និងកុមារដែលរស់នៅក្នុងគ្រួសារដែលមានអំពើហិង្សាក្នុងគ្រួសារ និងកុមារដែលត្រូវគេរំលោភផ្លូវភេទ។ ជាបន្តអ្នកសម្របសម្រួលបន្ថែមថា ពេលនេះយើងនឹងពិភាក្សាអំពីកុមារដែលត្រូវគេកេងប្រវ័ញ្ចកម្លាំងពលកម្ម។ | |
| ១៥នាទី | **២. ការបំផុសសំណួរ និងការបង្ហាញ-ពន្យល់**<br>អ្នកសម្របសម្រួលចាប់ផ្ដើមដោយបំផុសសំណួរថា តើពលកម្មកុមារមានន័យយ៉ាងដូចម្ដេច? កត់ត្រាចម្លើយរបស់សិក្ខាកាម។ បន្ទាប់មកអ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅមេរៀនត្រង់ ៥.១.ពលកម្មកុមារ ហើយស្នើឱ្យសិក្ខាកាមម្នាក់អានខ្លាំងៗ រួចធ្វើការពន្យល់ម្ដងមួយចំណុចៗ។ | ខ្លឹមសារមេរៀន ៥.១ |
| ១០នាទី | **៣. ការសួរសំណួរបំផុស**<br>អ្នកសម្របសម្រួលសួរសិក្ខាកាមថា តើនៅក្នុងឃុំ សង្កាត់របស់អ្នកមានកុមារដែលមានអាយុក្រោម១៨ឆ្នាំកំពុងតែធ្វើការងារដែរឬទេ? តើពួកគេធ្វើការនៅឯណា? អ្នកសម្របសម្រួលកត់ចម្លើយរបស់សិក្ខាកាមលើក្រដាសផ្ទាំងធំ ឬលើក្ដារខៀន។ | |

| រយៈពេល | សកម្មភាព | ធនធាន |
| --- | --- | --- |
| | **ចម្លើយអាចមាន :**<br>• សិប្បកម្មឡឥដ្ឋ ✓<br>• រោងចក្រកែច្នៃត្រី ✓<br>• ធ្វើការនៅក្នុងកសិដ្ឋាន<br>• ដឹកជញ្ជូនឆ្លងកាត់ព្រំដែន (ដឹកចូន់១) ✓<br>• រោងចក្រកាត់ដេរសំលៀកបំពាក់<br>• ជួយកិច្ចការផ្ទះ<br>• ស្រែអំបិល ✓<br>• ឃ្វាលគោ ក្របី<br>• ចំការកៅស៊ូ✓<br>• មើលថែប្អូនៗ<br>• ភោជនីយដ្ឋាននិងសណ្ឋាគារ✓<br>• កន្លែងគំនរសំរាម ✓<br>អ្នកសម្របសម្រួលសួរបន្តទៀតថា តើទីកន្លែងណាខ្លះដែលអ្នកចាត់ទុកថាជាកន្លែងមានគ្រោះថ្នាក់ធ្ងន់ធ្ងរសម្រាប់កុមារ? តាមការផ្តល់យោបល់របស់សិក្ខាកាម អ្នកសម្របសម្រួលគូសសញ្ញា ✓ លើចម្លើយដែលបានសរសេរនៅលើក្តារខៀន។<br><br>បន្ថែមលើចម្លើយ អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច **៥.២.ការងារដែលមានការកេងប្រវ័ញ្ច និងមានគ្រោះថ្នាក់** ហើយធ្វើការពន្យល់ម្តងមួយចំណុចៗ។ | ខ្លឹមសារ មេរៀន ៥.២ |
| ១០នាទី | **៤. ការបំផុសសំណួរ**<br>អ្នកសម្របសម្រួលបន្តដោយសួរសំណួរបំផុសថា **តើពលកម្មកុមារផ្តល់ផលប៉ះពាល់អ្វីខ្លះដល់កុមារ?** ក្នុងការសួរសំណួរបំផុស អ្នកសម្របសម្រួលអាចប្រើវិធីសាស្ត្រក្រដាសកាត១គំនិត១ក៏បាន ហើយកត់ត្រាចម្លើយលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ បន្ទាប់មកស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច **៥.៣.ផលប៉ះពាល់ពីការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ** ហើយធ្វើការពន្យល់ម្តងមួយចំណុចៗ។ | ក្រដាសកាត<br><br>ខ្លឹមសារ មេរៀន ៥.៣ |
| ១៥នាទី | **៥. ការសួរសំណួរបំផុស និងបង្ហាញ**<br>អ្នកសម្របសម្រួលបន្តដោយសួរសំណួរបំផុសថា **ក្នុងនាមជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គណៈកម្មការទទួលបន្ទុកកិច្ចការនារីនិងកុមារ និងអ្នកតំណាងភូមិ តើអ្នកអាចធ្វើអ្វីបានខ្លះ ដើម្បីដោះស្រាយបញ្ហាការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារនៅក្នុងឃុំ សង្កាត់របស់អ្នក?**<br><br>អ្នកសម្របសម្រួលកត់ត្រាចម្លើយរបស់សិក្ខាកាម រួចស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច **៥.៤.ការអន្តរាគមន៍** ហើយធ្វើការពន្យល់ម្តងមួយចំណុចៗ។ | ខ្លឹមសារ មេរៀន៥.៤ |

| រយៈពេល | សកម្មភាព | ធនធាន |
| --- | --- | --- |
| ១០នាទី | **៦. ការបង្ហាញ និងធ្វើសុពលភាព**<br>អ្នកសម្របសម្រួលចែកឯកសារ ៥.១.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្ដល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមនៅក្នុងឯកសារ ៥.១ នូវសកម្មភាពដែលគេចង់បន្ថែមនោះ។ | ឯកសារ៥.១. ផែនការសកម្មភាព |

## ឯកសារ ៥.១ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- ពេលនរណាម្នាក់សង្ស័យថា មានករណីពលកម្មកុមារកើតឡើង គេត្រូវផ្ដល់ដំណឹងទៅមេភូមិ ឬអ្នកស្ម័គ្រចិត្តសង្គមកិច្ចភូមិនៅតាមសហគមន៍ ឬអាជ្ញាធរមូលដ្ឋាន។
- ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវផ្សព្វផ្សាយ និងពន្យល់ឪពុកម្ដាយពីផលប៉ះពាល់នៃបញ្ហានេះ និងដាក់បញ្ចូលបញ្ហានេះទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់។ ករណីនេះអាចត្រូវបញ្ជូនទៅអ្នកត្រួតពិនិត្យពលកម្មកុមារនៃមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈខេត្ត ក្រុង ដែលនឹងត្រូវចាប់ផ្ដើមវិធានការតាមផ្លូវច្បាប់ដែលពាក់ព័ន្ធ។
- រាយការណ៍អំពីករណីនេះទៅអាជ្ញាធរមានសមត្ថកិច្ចដូចជា មន្ត្រីសង្គមកិច្ច និងមន្ត្រីការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ មេឃុំ ចៅសង្កាត់ នគរបាល ...។ល។
- ផ្សព្វផ្សាយអំពីល្បិចកលជនល្មើសដល់សហគមន៍ និងឃ្លាំមើលសកម្មភាពជនមុខសញ្ញា។
- ------------------------------------------------------------------------
- ------------------------------------------------------------------------
- ------------------------------------------------------------------------
- ------------------------------------------------------------------------
- ------------------------------------------------------------------------

# ប្លង់មេរៀនទី៦

## កុមារចាកចេញពីសហគមន៍ដោយគ្មានឪពុកម្តាយទៅជាមួយ

| | |
|---|---|
| គោលបំណង | ក្រោយពីបញ្ចប់មេរៀននេះ សិក្ខាកាមនឹងអាច ÷<br>• ដឹងពីមូលហេតុដែលនាំឱ្យកុមារចាកចេញពីសហគមន៍ដោយគ្មានឪពុកម្តាយទៅជាមួយ<br>• ដឹងពីភាពគ្រោះថ្នាក់ដែលកុមារចាកចេញពីសហគមន៍ដោយគ្មានឪពុកម្តាយទៅជាមួយ<br>• ចាត់វិធានការដើម្បីទប់ស្កាត់កុមារដែលចាកចេញពីសហគមន៍ដោយគ្មានឪពុកម្តាយទៅជាមួយក្នុងឃុំ សង្កាត់របស់ខ្លួន |
| រយៈពេលសរុប | ប្រហែល ៩០នាទី |
| សម្ភារ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ក្រដាសកាត ឯកសារ៦.១.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន |
| វិធីសាស្ត្រ | បំផុសគំនិត ពិភាក្សាជាគូ ពិភាក្សាក្រុមតូច ការបង្ហាញ និងពន្យល់ |
| សកម្មភាពសម្របសម្រួលមេរៀនៈ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | **១. ផ្តើមសេចក្តី**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា យើងបានពិភាក្សាជាមួយគ្នាហើយ អំពីកុមារដែលត្រូវការកិច្ចការពារពិសេស កុមារកំព្រា កុមារគេបោះបង់ចោល កុមារដែលរស់នៅក្នុងគ្រួសារដែលមានអំពើហិង្សាក្នុងគ្រួសារ កុមារដែលត្រូវគេរំលោភផ្លូវភេទ និងកុមារដែលត្រូវគេកេងប្រវ័ញ្ចកម្លាំងពលកម្ម។<br><br>ជាបន្តអ្នកសម្របសម្រួលបន្ថែមថា ពេលនេះយើងនឹងពិភាក្សាអំពី កុមារដែលចាកចេញពីសហគមន៍ដោយគ្មានឪពុកម្តាយទៅជាមួយ។ | |
| ១០នាទី | **២. ការសួរសំណួរបំផុស និងបង្ហាញ**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយដោយសួរសំណួរបំផុសថា តើមានកុមារចាកចេញទៅក្រៅសហគមន៍ដោយគ្មានឪពុកម្តាយទៅជាមួយឬទេក្នុងឃុំ សង្កាត់របស់អ្នក? ជាទូទៅសិក្ខាកាមឆ្លើយថាមាន។ អ្នកសម្របសម្រួលបន្តសួរទៀតថា តើកុមារចាកចេញពីសហគមន៍ដោយគ្មានឪពុកម្តាយទៅជាមួយមានន័យយ៉ាងដូចម្តេច? កត់ត្រាចម្លើយនៅលើក្តារខៀន ឬក្រដាសផ្ទាំងធំ។<br><br>បន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលបន្ថែមថា "កុមារដែលចាកចេញពីសហគមន៍ដោយគ្មានឪពុកម្តាយទៅជាមួយ គឺជាការនាំកុមារចេញពី | ខ្លឹមសារមេរៀន ទំព័រទី២៥ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | លំនៅដ្ឋានដែលគេធ្លាប់រស់នៅជាប្រក្រតី ទៅកាន់កន្លែងផងទៃទៀតនៅក្នុងប្រទេស ឬក្រៅប្រទេស ដើម្បីគោលបំណងណាមួយដោយមិនមានឪពុកម្តាយទៅជាមួយ" (ខ្លឹមសារនេះមាននៅក្នុងសៀវភៅមេរៀនត្រង់ទំព័រ២៥) ។<br><br>អ្នកសម្របសម្រួលបន្តសួរបំផុសថា ហេតុអ្វីបានជាកុមារទាំងនេះចាកចេញទៅក្រៅសហគមន៍របស់គេ? អ្នកសម្របសម្រួលប្រើវិធីសាស្ត្រក្រដាសកាត១គំនិត១ ដោយចែកក្រដាសកាតទៅគ្រប់សិក្ខាកាមទាំងអស់ ហើយស្នើឱ្យសិក្ខាកាមម្នាក់សរសេរតែមួយចម្លើយប៉ុណ្ណោះ។ អ្នកសម្របសម្រួលត្រូវសរុបចម្លើយរបស់សិក្ខាកាម ហើយស្នើឱ្យសិក្ខាកាមបើកសៀវភៅមេរៀនត្រង់ចំណុច ៦.១.មូលហេតុដែលនាំឱ្យកុមារចាកចេញពីសហគមន៍ រួចធ្វើការពន្យល់ម្តងមួយចំណុចៗ។ | ខ្លឹមសារ<br>មេរៀន៦.១ |
| ១៥នាទី | **៣. ការពិភាក្សាជាដៃគូ**<br>អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមអង្គុយក្បែរៗគ្នា២នាក់ៗ ធ្វើការពិភាក្សាលើសំណួរថា នៅពេលដែលកុមារចាកចេញពីសហគមន៍ដោយគ្មានឪពុកម្តាយទៅជាមួយ តើកុមារត្រូវជួបនឹងគ្រោះថ្នាក់អ្វីខ្លះ? ទុកពេលឱ្យសិក្ខាកាមពិភាក្សារយៈពេល១០នាទី។ បន្ទាប់មកស្នើឱ្យសិក្ខាកាម ៤ទៅ៥គូផ្តល់ចម្លើយ ហើយស្នើឱ្យគូផ្សេងៗទៀតបន្ថែម បើគេមានចម្លើយបន្ថែម។<br><br>បន្ទាប់មក អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅមេរៀនត្រង់ចំណុច ៦.២.ភាពគ្រោះថ្នាក់ ហើយធ្វើការពន្យល់ម្តងមួយចំណុចៗ។ | ក្រដាសកាត<br><br>ខ្លឹមសារ<br>មេរៀន៦.២ |
| ៥០នាទី | **៤. ការពិភាក្សាក្រុម**<br>អ្នកសម្របសម្រួលបែងចែកសិក្ខាកាមជា ៣ក្រុម តាមវិធីសាស្ត្រផ្សេងៗដើម្បីធ្វើការពិភាក្សាលើសំណួរផ្សេងៗគ្នាដូចខាងក្រោម :<br>• ក្រុមទី១ : ក្នុងករណីកុមាររត់ចេញពីផ្ទះ តើត្រូវដោះស្រាយយ៉ាងដូចម្តេច?<br>• ក្រុមទី២ : ក្នុងករណីកុមារចាកចេញពីផ្ទះទៅរកការងារធ្វើ តើត្រូវដោះស្រាយយ៉ាងដូចម្តេច?<br>• ក្រុមទី៣ : ក្នុងករណីកុមារត្រូវគេបោកប្រាសយកចេញទៅក្រៅសហគមន៍ តើត្រូវដោះស្រាយយ៉ាងដូចម្តេច? | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | អ្នកសម្របសម្រួលទុករយៈពេល២០នាទី សម្រាប់ការពិភាក្សានេះ។ បន្ទាប់មកស្នើឱ្យតំណាងក្រុមនីមួយឡើងបង្ហាញលទ្ធផលរបស់ខ្លួន។<br><br>ដើម្បីបំពេញបន្ថែមលើចម្លើយរបស់សិក្ខាកាម អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅមេរៀនត្រង់ចំណុច ៦.៣.ដំណោះស្រាយ ហើយធ្វើការពន្យល់ម្តងមួយចំណុចៗ។ ក្នុងការពន្យល់ អ្នកសម្របសម្រួលអាចស្នើឱ្យសិក្ខាកាមម្នាក់អានខ្លឹមសារខ្លាំងៗជាមុនក៏បាន។<br><br>អ្នកសម្របសម្រួលបញ្ជាក់ថា បើកុមារចាកចេញទៅក្រៅផ្ទះដោយឪពុកម្តាយដឹង ឬពុំដឹង ដើម្បីទៅស្វែងរកការងារធ្វើនៅទីក្រុង ទីប្រជុំជន ឬក៏អាចឆ្លងដែនទៅប្រទេសជិតខាង ហើយបាត់ដំណឹង ឬបាត់ទំនាក់ទំនងជាមួយគ្រួសារ ឪពុកម្តាយកុមារនោះត្រូវជូនព័ត៌មានទៅមេភូមិ មេឃុំ ចៅសង្កាត់ គ.ក.ន.ក ដោយភ្ជាប់រូបថតរបស់កុមារនោះផង ដើម្បីបញ្ជូនទៅមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ឱ្យជួយស្វែងរកកុមារតាមខ្សែបណ្តោយព្រោះថា មានអង្គការមិនមែនរដ្ឋាភិបាលជាច្រើនបានចុះកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីផ្តល់សេវាសង្គ្រោះកុមាររងគ្រោះគ្រប់ប្រភេទ។ | ខ្លឹមសារ មេរៀន ៦.៣ |
| ១០នាទី | **៥. ការបង្ហាញ និងធ្វើសុពលភាព**<br>អ្នកសម្របសម្រួលចែកឯកសារ ៦.១.**ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន** ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមនៅក្នុងឯកសារ ៦.១ នូវសកម្មភាពដែលគេចង់បន្ថែមនោះ។ | ឯកសារ៦.១. ផែនការ សកម្មភាព |

## ឯកសារ ៦.១ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- ទប់ស្កាត់រាល់ទង្វើទាំងឡាយរបស់អ្នកបោកប្រាស់ ដែលមានគោលបំណងនាំកុមារចេញទៅក្រៅសហគមន៍
- ជំរុញឪពុកម្តាយឱ្យស្វែងរកព័ត៌មាន និងទីកន្លែងជាក់លាក់របស់កុមារដែលចាកចេញទៅក្រៅសហគមន៍
- លើកទឹកចិត្តពាណិជ្ជករក្នុងមូលដ្ឋាន ឱ្យជ្រើសរើសកុមារវ័យជំទង់ ដើម្បីរៀនធ្វើការងារយកបទពិសោធន៍
- ស្វែងរកការងារសមស្របសម្រាប់កុមារវ័យជំទង់
- បញ្ចូលកុមារទៅក្នុងសកម្មភាពនានារបស់សហគមន៍
- ទាក់ទងជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលមានលទ្ធភាពជួយដល់កុមារ
- ពន្យល់កុមារ និងឪពុកម្តាយអំពីផលប៉ះពាល់អវិជ្ជមាននៃការចាកចេញទៅក្រៅសហគមន៍
- ផ្សព្វផ្សាយដល់អ្នកភូមិជាពិសេសកុមារ អំពីល្បិចកលឈ្មួញជួញដូរកុមារ និងវិធីការពារខ្លួនដោយខ្លួនឯង
- បង្កើតប្រព័ន្ធសង្គមកិច្ចដែលមានប្រសិទ្ធភាព ឬពង្រឹងសេវាសង្គមកិច្ចនៅក្នុងតំបន់ដែលមានការទាក់ទាញកុមារ តំបន់ទេសចរណ៍ ទីក្រុង ... (អនុវត្តបាននៅក្នុងឃុំមួយចំនួនប៉ុណ្ណោះ) ។
- ------------------------------------------------------------------------------------------------
- ------------------------------------------------------------------------------------------------
- ------------------------------------------------------------------------------------------------
- ------------------------------------------------------------------------------------------------
- ------------------------------------------------------------------------------------------------

# ប្លង់មេរៀនទី៧

## កុមារពិការ

| | |
|---|---|
| គោលបំណង | ក្រោយពីបញ្ចប់មេរៀននេះ សិក្ខាកាមនឹង ÷<br>• ដឹងពីអត្តសញ្ញាណនៃពិការភាពរបស់កុមារ<br>• ដឹងពីភាពរងគ្រោះ និងការឆ្លើយតបចំពោះកុមារពិការ<br>• ចាត់វិធានការសមស្របដើម្បីជួយដល់កុមារពិការក្នុងឃុំ សង្កាត់របស់ខ្លួន |
| រយៈពេលសរុប | ប្រហែល ៦០នាទី |
| សម្ភារ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ឯកសារ៧.១.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន |
| វិធីសាស្ត្រ | បំផុសគំនិត ពិភាក្សាក្រុមធំ ការបង្ហាញ និងពន្យល់ |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | **១. ផ្តើមសេចក្តី**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា យើងបានពិភាក្សាជាមួយគ្នាហើយ អំពីកុមារដែលត្រូវការកិច្ចការពារពិសេស កុមារកំព្រានិងកុមារគេបោះបង់ចោល និង កុមារដែលរស់នៅក្នុងគ្រួសារដែលមានអំពើហិង្សាក្នុងគ្រួសារ កុមារដែលត្រូវគេ រំលោភផ្លូវភេទ កុមារដែលត្រូវគេកេងប្រវ័ញ្ចកម្លាំងពលកម្ម និងកុមារដែលចាកចេញ ពីសហគមន៍ដោយគ្មានឪពុកម្តាយទៅជាមួយ។ ជាបន្តអ្នកសម្របសម្រួលបន្ថែមថា ពេលនេះយើងនឹងពិភាក្សាអំពី **កុមារពិការ**។ | |
| ៥នាទី | **២. ការបំផុសសំណួរ និងបង្ហាញអំពីនិយមន័យ**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយសួរសំណួរបំផុសថា តើកុមារពិការមានន័យយ៉ាង ដូចម្តេច? កត់ត្រាចម្លើយលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ បន្ទាប់មកស្នើឱ្យសិក្ខាកាម បើកសៀវភៅត្រង់ទំព័រ៣០ (**កុមារពិការ និងពិការភាព**) ហើយធ្វើការពន្យល់ម្តង មួយចំណុចៗ។ | ខ្លឹមសារមេរៀន ទំព័រទី៣០ |
| ៥នាទី | ៣. ការសួរសំណួរបំផុស<br>អ្នកសម្របសម្រួលសួរសំណួរបំផុសថា តើអ្នកធ្លាប់ដឹង និងឃើញកុមារពិការដែរ ឬទេ? ពិការលើអ្វីខ្លះ? កត់ត្រាចម្លើយរបស់សិក្ខាកាម។<br>ចម្លើយអាចមានដូចជា :<br>• កុមារពិបាកក្នុងការមើល | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | • កុមារពិបាកក្នុងការស្តាប់<br>• កុមារពិបាកក្នុងការនិយាយ<br>• កុមារពិបាកក្នុងការធ្វើចលនា<br>• កុមារពិបាកកាយវិញ្ញាណ<br>• កុមារពិបាកខាងផ្លូវចិត្ត<br>• កុមារពិបាកក្នុងការរៀនសូត្រ<br>• កុមារមានជំងឺប្រកាច់ (ឆ្កួតជ្រូក)<br>• ពិការផ្សេងៗទៀត | |
| ២០នាទី | **៤. ការបង្ហាញ និងពន្យល់**<br>បន្ថែមលើការពិភាក្សាខាងលើ អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅមេរៀនត្រង់ចំណុច **៧.១.ប្រភេទ និងលក្ខណៈពិការភាពរបស់កុមារ** ហើយធ្វើការពន្យល់ម្តងមួយចំណុចៗ។ ក្នុងការពន្យល់ អ្នកសម្របសម្រួលអាចស្នើឱ្យសិក្ខាកាមម្នាក់អានខ្លឹមសារមេរៀនខ្លាំងៗរួចទើបធ្វើការពន្យល់ក៏បាន។ | ខ្លឹមសារមេរៀន៧.១ |
| ១៥នាទី | **៥. ការសួរសំណួរបំផុស និងការបង្ហាញ**<br>អ្នកសម្របសម្រួលបន្តសួរសំណួរបំផុសថា **តើហេតុអ្វីបានជាកុមារពិការតែងទទួលរងគ្រោះ? ឬតើកុមារពិការទទួលរងគ្រោះអ្វីខ្លះ?** កត់ត្រាចម្លើយរបស់សិក្ខាកាមលើក្តារខៀន ឬក្រដាសផ្ទាំងធំ។<br><br>បន្ទាប់មកទៀត អ្នកសម្របសម្រួលបន្តសួរសំណួរថា **តើយើងត្រូវឆ្លើយតបយ៉ាងដូចម្តេចចំពោះកុមារពិការ?** កត់ត្រាចម្លើយរបស់សិក្ខាកាម។ ដើម្បីបំពេញបន្ថែមនូវចម្លើយរបស់សិក្ខាកាមលើសំណួរទាំងពីរខាងលើ អ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅមេរៀនត្រង់ចំណុច **៧.២.ភាពរងគ្រោះរបស់កុមារពិការ** និង **៧.៣.ការឆ្លើយតបចំពោះកុមារពិការ** ហើយធ្វើការពន្យល់ម្តងមួយចំណុចៗ។ | ខ្លឹមសារមេរៀន ៧.២ និង៧.៣ |
| ១០នាទី | **៥.ការបង្ហាញ និងធ្វើសុពលភាព**<br>អ្នកសម្របសម្រួលចែកឯកសារ **៧.១.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន** ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមនៅក្នុងឯកសារ ៧.១ នូវសកម្មភាពដែលគេចង់បន្ថែមនោះ។ | ឯកសារ៧.១. ផែនការសកម្មភាព |

## ឯកសារ ៧.១. ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- រៀបចំឱ្យមានបង្គន់អនាម័យពិសេសសម្រាប់កុមារពិការនៅតាមសាលារៀន
- បង្កើតឱ្យមានផ្លូវជំរាលសម្រាប់កុមារប្រើប្រាស់រទេះកង់
- បញ្ជូនកុមារពិការដែលមានលទ្ធភាពទៅផ្សព្វផ្សាយនៅសាលារៀន
- ត្រូវមានសាលារៀន ឬថ្នាក់ជំនាញពិសេសសម្រាប់កុមារពិការ
- លើកទឹកចិត្តដល់ឪពុកម្តាយឱ្យថែទាំកូនរបស់គេដែលពិការ និងយកចិត្តទុកដាក់ចំពោះពួកគេឱ្យបានប្រសើរ ឬក៏ប្រសើរជាងក្មេងដទៃ
- ផ្សព្វផ្សាយដល់សហគមន៍កុំឱ្យរើសអើងចំពោះកុមារពិការ
- ករណីចាំបាច់ ត្រូវទំនាក់ទំនងជាមួយមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ ដើម្បីបញ្ជូនកុមារទៅរកសេវាព្យាបាល ផ្តល់រទេះ ឬឈើច្រត់ ជាដើម
- ------------------------------------------------------------------------------------------
- ------------------------------------------------------------------------------------------
- ------------------------------------------------------------------------------------------
- ------------------------------------------------------------------------------------------
- ------------------------------------------------------------------------------------------

# ប្លង់មេរៀនទី៨

# កុមារទំនាស់នឹងច្បាប់

| | |
|---|---|
| គោលបំណង | ក្រោយពីបញ្ចប់មេរៀននេះ សិក្ខាកាមនឹង ÷<br>• ដឹងអំពីបញ្ហាកុមារទំនាស់នឹងច្បាប់<br>• ចាត់វិធានការដើម្បីជួយដល់កុមារទំនាស់នឹងច្បាប់ក្នុងឃុំ សង្កាត់របស់ខ្លួន |
| រយៈពេលសរុប | ប្រហែល ៦៥នាទី |
| សម្ភារ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត រូបភាព ឯកសារ៨.១.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន |
| វិធីសាស្ត្រ | បំផុសគំនិត ការបង្ហាញ និងពន្យល់ |

សកម្មភាពសម្របសម្រួលមេរៀន :

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ៥នាទី | **២. ការសួរសំណួរបំផុស**<br>អ្នកសម្របសម្រួលសួរសំណួរបំផុសទៅសិក្ខាកាមថា តើកុមារទំនាស់នឹងច្បាប់មានន័យយ៉ាងដូចម្តេច? កត់ត្រាចម្លើយរបស់សិក្ខាកាមលើក្តារខៀន ឬក្រដាសផ្ទាំងធំ។ បន្ថែមលើចម្លើយលើរបស់សិក្ខាកាម អ្នកសម្របសម្រួលបន្ថែមថា "កុមារទំនាស់នឹងច្បាប់ គឺកុមារដែលត្រូវបានសង្ស័យ ចោទប្រកាន់ ឬទទួលស្គាល់ថាបានប្រព្រឹត្តបទល្មើស។ កុមារបែបនេះត្រូវទទួលបាននូវការប្រព្រឹត្តពិសេសមិនដូចនឹងជនល្មើសដែលជាមនុស្សពេញវ័យឡើយ" (ខ្លឹមសារនេះមាននៅក្នុងសៀវភៅមេរៀនត្រង់ទំព័រទី៣៦) ហើយធ្វើការពន្យល់។ | ខ្លឹមសារមេរៀន ទំព័រទី៣៦ |
| ៣៥នាទី | **៣. ការបង្ហាញរូបភាព និងពន្យល់អត្ថន័យ**<br>អ្នកសម្របសម្រួលធ្វើការបង្ហាញរូបភាពកុមារទំនាស់នឹងច្បាប់ទី១ដល់ទី៥ម្តងមួយៗ តាមលំដាប់លំដោយ ហើយសួរទៅសិក្ខាកាមថា :<br>• តើអ្នកបានឃើញអ្វីខ្លះនៅក្នុងរូបភាពនីមួយៗ?<br>• តើរូបភាពនីមួយៗមានអត្ថន័យយ៉ាងដូចម្តេច?<br><br>កត់ត្រាចម្លើយរបស់សិក្ខាកាមលើក្តារខៀន ឬក្រដាសផ្ទាំងធំ ។<br>ចម្លើយអាចមាន :<br>• រូបទី១ : ការប្រព្រឹត្តរបស់នគរបាល<br>• រូបទី២ : មុនពេលជំនុំជម្រះ និងការឃុំខ្លួន | រូបភាពកុមារទំនាស់នឹងច្បាប់ (ទី១ ដល់ទី៥) |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | • រូបទី៣ : កុមារមានសិទ្ធិរកមេធាវីជាតំណាង<br>• រូបទី៤ : កុមារជាជនល្មើសអាចរស់នៅជាមួយគ្រួសារ<br>• រូបទី៥ : ល័ក្ខខ័ណ្ឌនៃការឃុំខ្លួន និងការដាក់កុមារក្នុងស្ថាប័ន<br><br>បន្ទាប់មក អ្នកសម្របសម្រួល ស្នើឱ្យសិក្ខាកាមបើកសៀវភៅមេរៀនត្រង់ចំណុច ៨.១.ការប្រព្រឹត្តរបស់នគរបាលទៅលើកុមារ ៨.២.ការជំនុំជម្រះរឿងក្តី និងការឃុំខ្លួន ហើយធ្វើការពន្យល់ម្តងមួយចំណុចៗ ដោយបង្ហាញរូបភាពឡើងវិញម្តងមួយៗតាមលំដាប់លំដោយនៃរូបភាពនោះជាមួយខ្លឹមសារមេរៀន ។ | ខ្លឹមសារមេរៀន ៨.១ និង៨.២ |
| ១៥នាទី | **៤. ការបង្ហាញ និងពន្យល់**<br>ជាបន្តអ្នកសម្របសម្រួលស្នើឱ្យសិក្ខាកាមបើកសៀវភៅត្រង់ចំណុច ៨.៣.ចំណុចគួរចងចាំ ហើយស្នើឱ្យសិក្ខាកាមម្នាក់អានខ្លាំងៗ និងពន្យល់ម្តងមួយចំណុចៗ ។ | ខ្លឹមសារ មេរៀន៨.៣ |
| ១០នាទី | **៥. ការបង្ហាញ និងធ្វើសុពលភាព**<br>អ្នកសម្របសម្រួលចែកឯកសារ ៨.១.ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន ហើយធ្វើការបង្ហាញ និងធ្វើសុពលភាពជាមួយសិក្ខាកាម ។ អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមបន្ថែមសកម្មភាពនានា និងស្នើសុំឱ្យសិក្ខាកាមសរសេរចូលបន្ថែមនៅក្នុងឯកសារ ៨.១ នូវសកម្មភាពដែលគេចង់បន្ថែមនោះ ។ | ឯកសារ៨.១. ផែនការសកម្មភាព |

# រូបភាពការប្រព្រឹត្តមកលើកុមារទំនាស់នឹងច្បាប់



រូបទី១



រូបទី២



រូបទី៣



រូបទី៤



រូបទី៥

## ឯកសារ ៨.១ : ផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន

- បញ្ជូនកុមារ និងឪពុកម្តាយកុមារទៅស្ថាប័ន ឬភ្នាក់ងារដែលអាចជួយគេបាន ដូចជា អង្គការមិនមែនរដ្ឋាភិបាល និងមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ
- ទៅសួរសុខទុក្ខឪពុកម្តាយ និងកុមារជាទៀងទាត់ និងផ្តល់ការគាំទ្រដែលអ្នកអាចធ្វើបាន
- ផ្តល់ដំណឹង និងការតវ៉ាពីកុមារដែលមានទំនាស់នឹងច្បាប់ ឬពីឪពុកម្តាយទៅអាជ្ញាធរថ្នាក់លើបើមានការស្នើសុំ
- ទប់ស្កាត់ និងធានាថាគ្មានការរើសអើងពីសំណាក់សហគមន៍ចំពោះកុមារ ឬឪពុកម្តាយ
- គាំទ្រសកម្មភាពយុវជន ដើម្បីបង្ការកុំឱ្យកុមារប្រព្រឹត្តបទល្មើស ឬប្រព្រឹត្តបទល្មើសសារជាថ្មី
- ------------------------------------------------------------------------------------------
- ------------------------------------------------------------------------------------------
- ------------------------------------------------------------------------------------------
- ------------------------------------------------------------------------------------------
- ------------------------------------------------------------------------------------------

# ប្លង់មេរៀនទី៩

## ការបូកសរុបផែនការសកម្មភាព

| | |
|---|---|
| គោលបំណង | ក្រោយពីបញ្ចប់មេរៀននេះ សិក្ខាកាមនឹង ÷<br>• ពិនិត្យឡើងវិញអំពីសកម្មភាពនានាដែលបានពិភាក្សានៅក្នុងមេរៀនកន្លងមក<br>• ចាត់អាទិភាពសកម្មភាពទាំងនោះ និងកំណត់អ្នកទទួលខុសត្រូវក្នុងការរៀបចំ និងទទួលខុសត្រូវក្នុងការអនុវត្ត<br>• ដាក់បញ្ចូលសកម្មភាពដែលបានព្រមព្រៀងទៅក្នុងផែនការសកម្មភាពប្រចាំខែរបស់ខ្លួន<br>• ព្រមព្រៀងដាក់បញ្ចូលបញ្ហាកិច្ចការពារកុមារទៅក្នុងរបៀបវារៈនៃការប្រជុំជាទៀងទាត់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ |
| រយៈពេលសរុប | ប្រហែល ១២០នាទី |
| សម្ភារ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត ឯកសារ៩.១.សេចក្ដីព្រាងផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋាន |
| វិធីសាស្ត្រ | ការបង្ហាញ និងការពិភាក្សាក្រុមតូច។ |

**សកម្មភាពសម្របសម្រួលមេរៀន :**

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ២០នាទី | **១. ការបង្ហាញ និងពន្យល់ពីផែនការសកម្មភាព**<br>អ្នកសម្របសម្រួលចាប់ផ្ដើមដោយលើកឡើងថា នៅក្នុងរយៈពេលជិតពីរថ្ងៃកន្លងទៅនេះ យើងទាំងអស់គ្នាបានពិភាក្សាអំពីបញ្ហាជាច្រើន និងបានលើកឡើងនូវផែនការសកម្មភាពរបស់អាជ្ញាធរមូលដ្ឋានក្នុងបញ្ហាកិច្ចការពារកុមារ។ នៅពេលនេះ យើងធ្វើការបូកសរុបសកម្មភាពទាំងនោះឡើងវិញ។<br><br>បន្ទាប់មកអ្នកសម្របសម្រួលចែកឯកសារ ៩.១.សេចក្ដីព្រាងផែនការសកម្មភាព **របស់អាជ្ញាធរមូលដ្ឋាន** ហើយធ្វើសុពលភាពនៃសកម្មភាពទាំងនោះជាមួយសិក្ខាកាម។ នៅក្នុងការពិភាក្សានេះ សិក្ខាកាមអាចស្នើឱ្យលុប ឬបន្ថែមសកម្មភាពបាន។<br><br>បន្ទាប់ពីព្រមព្រៀងទៅលើសកម្មភាពហើយ អ្នកសម្របសម្រួលត្រូវពន្យល់ពីរបៀបបំពេញកូឡោនទី៣ ទី៤ និងទី៥ នៃឯកសារ៩.១.ដោយលើកឧទាហរណ៍មកបញ្ជាក់ជូនសិក្ខាកាម។ | ឯកសារ៩.១ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១០០នាទី | ២. ការពិភាក្សាក្រុម<br>អ្នកសម្របសម្រួលចែកសិក្ខាកាមតាមឃុំ សង្កាត់នីមួយៗ ដើម្បីពិភាក្សាអំពីផែនការសកម្មភាពរបស់ឃុំ សង្កាត់ខ្លួន។ ក្រុមនីមួយៗមានរយៈពេល៨០នាទី ដើម្បីធ្វើការពិភាក្សា។ ក្នុងការពិភាក្សាក្រុមនីមួយៗត្រូវបញ្ចូលសកម្មភាពនានាដែលខ្លួនយល់ថាសំខាន់ និងចាំបាច់។<br><br>ក្នុងពេលពិភាក្សា អ្នកសម្របសម្រួលត្រូវពិនិត្យមើលក្រុមនីមួយៗ ហើយជួយដល់ក្រុមណាដែលមិនទាន់យល់ច្បាស់។ តំណាងក្រុមឡើងបង្ហាញលទ្ធផលក្រុមរបស់ខ្លួន ហើយបន្ទាប់មក អ្នកសម្របសម្រួលបូកសរុបដោយធ្វើការបំពេញបន្ថែម និងបំភ្លឺនូវរាល់ចំណុចទាំងឡាយដែលសិក្ខាកាមមិនទាន់យល់ច្បាស់។ | |

### ឧបករណ៍សម្រាប់ពន្យល់ ៩.១. ផែនការសកម្មភាពរបស់ឃុំ សង្កាត់.....................នៅក្នុងកិច្ចការពារកុមារ

| លរ | សកម្មភាព | អ្នកចាត់ចែងសកម្មភាព | អ្នកអនុវត្តសកម្មភាព | កំណត់សម្គាល់ផ្សេង |
|---|---|---|---|---|
| | ស្រង់សកម្មភាពនានាដែលបានឯកភាពចូលក្នុងកូឡោននេះ ។ | ឈ្មោះ តួនាទីអ្នកដែលទទួលខុសត្រូវក្នុងការរៀបចំ ឬចាត់ចែងសកម្មភាព ។ | ឈ្មោះ តួនាទីអ្នកដែលទទួលខុសត្រូវក្នុងការអនុវត្តសកម្មភាពផ្ទាល់ ។ | ព័ត៌មានបន្ថែមដូចជា ពេលវេលា អ្នក ឬអង្គភាពរួមសហការ . . . ។ល ។ |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |
| | | | | |

## ៩.១. សេចក្តីព្រាងផែនការសកម្មភាពរបស់ឃុំ សង្កាត់......................នៅក្នុងកិច្ចការពារកុមារ

| ល.រ | សកម្មភាព | អ្នកចាត់ចែងសកម្មភាព | អ្នកអនុវត្តសកម្មភាព | កំណត់សម្គាល់ផ្សេង |
|---|---|---|---|---|
| ១ | ធ្វើការផ្សព្វផ្សាយដល់សហគមន៍អំពី :<br>• សារៈសំខាន់នៃការចុះសំបុត្រកំណើត<br>• ផលវិបាកនៃការរំលោភផ្លូវភេទលើកុមារ<br>• របៀបសម្គាល់អាការៈរបស់កុមារដែលត្រូវគេចាប់រំលោភផ្លូវភេទ<br>• ទីកន្លែងផ្តល់ប្រឹក្សាយោបល់ និងសេវាថែទាំសុខភាព<br>• ភាពខុសច្បាប់នៃការទំនាក់ទំនងផ្លូវភេទជាមួយកុមារ<br>• ផលប៉ះពាល់អវិជ្ជមាននៃពលកម្មកុមារ<br>• ល្បិចកលជនល្មើស និងរបៀបឃ្លាំមើលសកម្មភាពជនមុខសញ្ញា<br>• ផលប៉ះពាល់អវិជ្ជមាននៃកុមារដែលចាកចេញទៅក្រៅសហគមន៍ ដោយគ្មានឪពុកម្តាយទៅជាមួយ<br>• ការមិនរើសអើងចំពោះកុមារពិការ និងកុមាររងគ្រោះ | | | |
| ២ | ចុះសំបុត្រកំណើតឱ្យកុមារ តាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ | | | |
| ៣ | ទំនាក់ទំនងជាមួយ :<br>• អាចារ្យវត្ត ព្រះសង្ឃ ឬអង្គការ ស្ថាប័ននានា ដើម្បីផ្តល់អាហារ និងទីជម្រកដល់កុមាររងគ្រោះ<br>• នាយកសាលា ដើម្បីឱ្យកុមាររងគ្រោះអាចចូលរៀន<br>• អាជ្ញាធរ ឬមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌដើម្បីស្វែងរកឪពុកម្តាយ និងរកសេវាសមស្របនានាក្នុងករណីចាំបាច់ | | | |

| លរ | សកម្មភាព | អ្នកចាត់ចែងសកម្មភាព | អ្នកអនុវត្តសកម្មភាព | កំណត់សម្គាល់ផ្សេង |
|---|---|---|---|---|
| | • មន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ និងអ្នកពាក់ព័ន្ធនានាបញ្ជូនជនរងគ្រោះទៅរកសេវាប្រឹក្សាយោបល់ សេវាព្យាបាល និងឧបករណ៍សម្រាប់កុមារពិការ ដូចជា រទេះ ឈើច្រត់ ... | | | |
| ៤ | ផ្តល់សេវាជួយដល់កុមាររងគ្រោះតាមរយៈ :<br>• បញ្ជូនកុមាររងគ្រោះទៅមន្ទីរពេទ្យ និងទៅមន្ត្រីសង្គមកិច្ចស្រុក ខណ្ឌ<br>• ផ្តល់ប្រឹក្សា ពិគ្រោះយោបល់ និងលើកទឹកចិត្តដល់កុមាររងគ្រោះ<br>• ឃ្លាំមើល និងតាមដានអ្នកដែលប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ<br>• ទាក់ទងជាមួយអង្គការមិនមែនរដ្ឋាភិបាល ដែលមានលទ្ធភាពជួយដល់កុមារ<br>• ឃាត់ខ្លួនជនល្មើសរួចបញ្ជូនទៅអាជ្ញាធរមានសមត្ថកិច្ច<br>• ស្វែងរកការងារសមស្របសម្រាប់កុមារវ័យជំទង់<br>• បញ្ចូលកុមារទៅក្នុងសកម្មភាពនានារបស់សហគមន៍<br>• រៀបចំឱ្យមានបង្គន់អនាម័យពិសេសសម្រាប់កុមារពិការនៅតាម សាលារៀន<br>• បង្កើតឱ្យមានផ្លូវជម្រាលសម្រាប់កុមារប្រើប្រាស់រទេះកង់<br>• រៀបចំឱ្យមានមានសាលារៀន ឬថ្នាក់ជំនាញពិសេសសម្រាប់កុមារពិការ | | | |
| ៥ | ទប់ស្កាត់រាល់ទង្វើទាំងឡាយរបស់អ្នកបោកប្រាស់ ដែលមានគោលបំណងនាំកុមារចេញទៅក្រៅសហគមន៍ | | | |
| ៦ | ជំរុញឪពុកម្តាយឱ្យស្វែងរកព័ត៌មាន និងទីកន្លែងជាក់លាក់របស់កុមារដែល ចាកចេញទៅក្រៅសហគមន៍ | | | |

| លរ | សកម្មភាព | អ្នកចាត់ចែងសកម្មភាព | អ្នកអនុវត្តសកម្មភាព | កំណត់សម្គាល់ផ្សេង |
|---|---|---|---|---|
| ៧ | លើកទឹកចិត្តពាណិជ្ជករក្នុងមូលដ្ឋាន ឱ្យជ្រើសរើសកុមារវ័យជំទង់ដើម្បីរៀនធ្វើការងារយកបទពិសោធន៍ | | | |
| ៨ | បង្កើតប្រព័ន្ធសង្គមកិច្ចដែលមានប្រសិទ្ធភាព ឬពង្រឹងសេវាសង្គមកិច្ចនៅក្នុងតំបន់ដែលមានការទាក់ទាញកុមារ តំបន់ទេសចរណ៍ ទីក្រុង . . . | | | |
| ៩ | បញ្ជូនកុមារពិការដែលមានលទ្ធភាពទៅផ្សព្វផ្សាយនៅសាលារៀន | | | |
| ១០ | លើកទឹកចិត្តដល់ឪពុកម្ដាយឱ្យថែទាំកូនរបស់គេដែលពិការ និងយកចិត្តទុកដាក់ចំពោះពួកគេឱ្យបានប្រសើរ ឬក៏ប្រសើរជាងក្មេងដទៃ | | | |
| ១១ | ផ្ដល់ដំណឹង និងការតវ៉ាពីកុមារដែលមានទំនាស់នឹងច្បាប់ ឬពីឪពុកម្ដាយទេ អាជ្ញាធរថ្នាក់លើ បើមានការស្នើសុំ | | | |
| ១២ | គាំទ្រសកម្មភាពយុវជន ដើម្បីបង្ការកុំឱ្យកុមារប្រព្រឹត្តបទល្មើស ឬប្រព្រឹត្តបទល្មើសសាជាថ្មីទៀត | | | |